# ការសំភាសន៍របស់បងប្រុស សួន នីន

កះ អ្នកធ្វើការសំភាសន៍គឺ អាង ប៊ុនសាយន្ត័ ខះ អ្នកត្រូវបានគេសំភាសន៍ សួននីន

កះ អញ្ចឹងជាដំបូងសូមថ្លែងអំណរគុណដល់បង នីន ដែលបានផ្តល់ពេលវេលានឹងការសហាការជាមួយខ្ញុំក្នុងការសំភាស៍ទាក់ទងពីជីវះប្រវិត្តនឹងជីវិតរបស់ពួកគាត់ដែរគាត់ធ្លាប់ឆ្លងកាត់តាំងពីនៅតូចមក។ហើយការសំភាសន៍នេះធ្វើឡើងនៅថ្ងៃទី១៨ខែតុលាឆ្នាំ២០១៧ ហើយអ្នកដែលសំភាសន៍គឺនាងខ្ញុំឈ្មោះ អាងប៊ុន សាយន្ត័ ហើយកាសំភាសន៍នេះគឺធ្វើនៅទីក្រុងតាខ្មៅ។អញ្ចឹងកុំអោយខាតពេលយូរខ្ញុំក៏សូមធ្វើការសំភាសន៍ជាមួយនឹងបងប្រុសតែម្តង។

កះ សួរស្តីបង។

ខះ បាទ!ជំរាបសួរ។

កះ បងអាចប្រាប់ឈ្មោះពេញរបស់បងបានទេទាំងត្រកូលហា៎ស?

ខះ ឈ្មោះពេញរបស់បងគឺឈ្មោះ សួន នីន។

កះ ចា៎ស។

ខះ បាទ។

កះ បងមានឈ្មោះហៅក្រៅរឺក៏ឈ្មោះដែលគេហៅពីតូចទេ?

ខះ ហៅក្រៅគេហៅក្នុងការរកស៊ីគេហៅ បងសរ ៗហា៎ស!។

កះ ចា៎ស។

ខះ បាទ។

កះ មានឈ្មោះអីផ្សេងទៀតអត់?

ខះ ពេលនៅរៀនគេហៅបង អាកោះធំ ដោយសារបងទើបតែផ្ទេរមករៀននៅអនិវិទ្យាល័យហា៎ស!ដល់អញ្ចឹងទៅបងនិយាយតាមតំបន់ហើយពេលបងនិយាយគេស្តាប់បានទៅថាអានេះអានោះអញ្ចឹងទៅណា៎។

កះ ចា៎ស។

ខះ ដល់អញ្ចឹងទៅគេហៅបង...មានអាពួកម៉ាកមួយជិតស្និតហ្នឹងគេហៅបងអាកោះធំៗហ្នឹង។

កះ ហើយចូលចិត្តឈ្មោះហ្នឹងគេហៅអត់ទេ?

ខះ បងដូចជាអត់ចូលចិត្តដែរតែគ្រាន់តែថាធ្វើម៉េចអានេះគ្រាន់តែជាការបាញ់គ្នាទៅវិញទៅមកគ្រាន់តែជាការលេងសើច។

កះ អានេះគ្រាន់តែជាលក្ខណះយើងលេងសើចកាលនៅតូចៗអីអញ្ចឹងហា៎ស។

ខះ បាទ!តែមួយហ្នឹងមួយទេតែពូម៉ាកហ្នឹងមួយទេដែលហៅហា៎ស!អញ្ចឹងបងគិតថាបងអត់ខឹងគេដោយសារគេស្រលាញ់យើងគេចូលចិត្តយើង។

កះ អញ្ចឹង!ហើយមកដល់សព្វថ្ងៃនេះតើបងមានអាយុប៉ុន្មានឆ្នាំដែរបង?

ខ៖ បង៧៣ហើយអូ!៣៧ឆ្នាំ។
ក៖ រាប់លេងបញ្ច្រាសមកវិញហោស?
ខ៖ បាទ។
ក៖ តើបងកើត...ថ្ងៃខែឆ្នាំកំណើតពេលណាវិញ?
ខ៖ បងកើតនៅថ្ងៃ១០ខែ០៧ឆ្នាំ១៩៨១។
ក៖ ចាំស!ចុះទាក់ទងជាមួយហ្នឹងកន្លែងកំណើតតើបងអាចប្រាប់ពីភូមិស្រុក?
ខ៖ បងកើតនៅភូមិក្បាលកោះធំឃុំកោះធំកស្រុកកោះធំខេត្តកណ្តាល។
ក៖ ចាំស!អញ្ចឹងសព្វថ្ងៃតើបងមានបងប្អូនប៉ុន្មាននាក់ដែរ?
ខ៖ រាល់ថ្ងៃមាន០៨នាក់។
ក៖ អូ!ច្រើនណាស់ណេ៎?
ខ៖ មានប្រុស០៦ស្រី០២នាក់។
ក៖ ចាំស!ហើយបងជាកូនទីប៉ុន្មាដែរនៅក្នុងក្រុមគ្រួសារ?
ខ៖ បងជាកូនទី០៤។
ក៖
ចាំស!អញ្ចឹងខ្ញុំក៏ចាប់អារម្មណ៍ផងដែរថាតើបងអាចជួយរៀបរាប់ឈ្មោះបងប្អូនរបសបងហាំស!តាំងពីទីមួយរហូតមកដល់ពៅហើយជួយរៀបរាប់ពីជីវិតរបស់ពួកគាត់ម្នាក់ៗផង។
ខ៖ បាទ!ទីមួយបងប្រុស សួន ណាត។
ក៖ ចាំស។
ខ៖ គាត់ជាអ្នកកិសិករចំម្មុងនៅខាងភូមិព្រែកឬស្សីស្រុកលើកដែកខេត្តកណ្តាល។
ក៖ ចាំស។
ខ៖
គាត់មានកូនស្រី០២ប្រុស០១ហើយរាល់ថ្ងៃគាត់រស់នៅឯខាងប្រពន្ធគាត់នៅឯភូមិព្រែកឬស្សីនោះ។
ក៖ ចាំស។
ខ៖
ហើយគាត់ធ្វើស្រែចំការគាត់ជាអ្នកស្រែចំការចំគាត់ចិញ្ចឹមគោចិញ្ចឹមអីអញ្ចឹងទៅ។ហើយបងទីពីរគាត់នៅតាខ្មៅជាមួយបងហ្នឹងគាត់នៅភូមិស្ទឹងជ្រៅភូមិដើមមានឃុំដើមមានស្រុកតាខ្មៅខេត្តកណ្តាលហ្នឹង។
ក៖ គាត់មានអាយុប៉ុន្មានហើយបង?
ខ៖ គាត់៤០ឆ្នាំជាងហើយគាត់ចូលមើស!...គាត់ចូល៤៣,៤៤ហើយគាត់ឆ្នាំកុរ។
ក៖ បងចាំថ្ងៃខែឆ្នាំកំណើតគាត់ទេ?
ខ៖
បងចាំតែឆ្នាំទេប៉ុន្តែរឿងថ្ងៃកំណើតគាត់បងមិនអាចចាំទេព្រោះអីបើម៉ែឪគាត់កាលពីមុនអត់បានកត់ដាក់គាត់អត់សូវបានកត់ចំណាំទេទាល់តែអញ្ចឹងចាំតែឆ្នាំគាត់។
ក៖ ចាំស។

ខ៖ ហ្នឹងហើយ។
ក៖ គាត់កើតនៅឆ្នាំណា?
ខ៖ ឆ្នាំជូត អូ!ឆ្នាំកុរច្រលំ..ឆ្នាំកុរហើយគាត់បានមកបន្តរការសិក្សាដូចបងដែរនៅស្នាក់នៅវត្តជាមួយព្រះសង្ឃនៅវត្តក្រពើហាហ្នឹងមុនដំបូង
ហើយក្រោយមកគាត់រៀនចប់គាត់ក៏បានប្រលងសិស្សពូកែទូទាំងប្រទេសជាប់ខាងផ្នែកខ្មែរអក្សរសាស្ត្រហាស!ហើយក៏បានរកការងារធ្វើក៏បានជាប់នៅណាកាវើលហ្នឹងជាប់រយះពេលជាង២០ឆ្នាំហ្នឹងបើគិតទៅយូរដែរតាំងពីនៅក្នុងកប៉ាលមក។
ក៖ គាត់ពូកែណាស់ណោះ?
ខ៖ បាទ!គាត់និយាយរួមភាពអំណត់គាត់ខ្លាំងណាស់ហើយគាត់មិនសូវចេះមាត់កអីច្រើនទេ។
ក៖ ចាស។
ខ៖ គាត់ជាមនុស្សមឹងម៉ាត់ជាងបងប្រុសជាងប្អូនប្រុសទាំងអស់ជាគំរូរមួយខ្លាំង។ហើយបងទីពីរអ៎!ទីបីគាត់នៅខាងកោះធំនៅស្រុកកំណើតហ្នឹងហ្មង។
ក៖ គាត់ឈ្មោះអីដែរបង?
ខ៖ គាត់ឈ្មោះ សួន ណេង,សួន ណាត,សួន ណិត,សួន ណេង។
ក៖ អាយុ?
ខ៖ គាត់មានអាយុអឺ!៤០មើល!...ឆ្នាំឆ្លូវគាត់៥១ឆ្នាំហើយអី?ឆ្លូវ១៥១...ហ្នឹងហើយ៥១ឆ្នាំ។គាត់មានកូនប្រុស០៣ប្រុសទាំង០៣
រាល់ថ្ងៃកូននៅក្នុងបន្ទុកគាត់មួយដែលរៀននៅសាកលវិទ្យាល័យហើយគាត់បានធ្វើនៅការដឹកជញ្ជូនគាត់មានឡានកូរ៉េមួយនៅស្រុកហ្នឹង។
ក៖ ចាស។
ខ៖ គាត់ធ្វើការដឹកជញ្ជូនដូចជាឈើនិយាយរួមទៅគាត់ស៊ីឈ្នួលហាស។
ក៖ ហ្នឹងហើយ។
ខ៖ ហើយគាត់ជួនកាលខែទឹកអញ្ចឹងគាត់ធ្វើទូកគាត់ធ្វើទូកលក់ហើយកូនពីរនាក់ទៀតគាត់នៅក្នុងបន្ទុកម្តាយគេ (ពួកគាត់បានចែកផ្លូវគ្នានោះ) ដល់អញ្ចឹងទៅកូនការចិញ្ចឹមផ្តល់អោយដូចថាមានការខ្វះខាតអីចេះតែផ្តល់អោយគ្នាអញ្ចឹងទៅណាស!។
ក៖ ចាស។
ខ៖ ហើយមកដល់ទីប្អូនបងហ្នឹងអែងជាកូនទីប្អូនឈ្មោះ សួន នីន ហ្នឹងនៅ..រាល់ថ្ងៃហ្នឹងបានប្រពន្ធអូ!..ទីមួយបងបានមកបន្តរការសិក្សាដែរនៅវត្តក្រពើហាហ្នឹងដែរក្រោយមកបងគាត់បានអោយទៅជួយការអារគាត់ហើយការអារគាត់គឺការចិញ្ចឹមជ្រូកហើយចិញ្ចឹមបន្ទើរអញ្ចឹងទៅហើយទៅរៀនបន្ទើរហើយពេលចេញពីរៀនបានទៅយកបាយ

ជ្រូកពីវត្តអញ្ចឹងទៅផ្ទះអញ្ចឹងទៅហើយដាក់បាយជ្រូកហើយធ្វើម្ហូបយកទៅអោយគាត់នៅផ្សារវិញជារឿយៗ ហើយដល់ម៉ោងរៀនយើងតៅរៀនទៅ។
កៈ ចាំស។
ខៈ មកវិញជួរៀបឥវ៉ានគេទុកដាក់ទៅហើយដឹកជញ្ជូនទោផ្ទះវិញទៅ។
កៈ តស៊ូណាស់បងណេ៎!ជីវិត?
ខៈ
បងបើនិយាយទៅវាខ្លាំងដែរដោយការចិញ្ចឹមបាយជ្រូកដោយការយួរធុងប៉េត្រូយួរដោយដៃបើគិតពីចំងាយទៅគិតពីវត្តក្រពើហារយើងទៅដល់ក្នុងភូមិស្ទឹងជ្រៅទៅដល់ផ្ទះយើងស្ពានឈើវាចូលមួយគីឡូដីជាងដែរណាស់។
កៈ ចាំស។
ខៈជាងមួយគីឡូដីដែរពេលចេញពីរៀនមកយើងដោះអាវចេញទៅកុំអោយប្រលាក់អាវហើយយើងយួរទៅដៃកាន់មួយចំហៀងយួរទៅហើយដៃមួយចំហៀងទៀតកាន់សៀវភៅហើយយួរទៅ។ហើយជារឿយៗក្រោយមកបានគាត់បានទិញកង់អោយមួយបានកង់ខ្មែរហ្នឹងបានេជិះទៅរៀនផងហើយដោយសារការបានដឹកបាយជ្រូកទើបយើងបានកង់ហ្នឹងជិះទៅរៀន
។
កៈ ចាំស។
ខៈ
ជិះបានរយៈពេលប៉ុន្មានដូចជាគេលួចរឺក៏ស្អីទេមួយរយៈពេលហ្នឹងបងដូចជាភ្លេចភ្លាំងដែរដោយសារអី?ដោយសារបងមួយរយៈពេលហ្នឹងគឺបងផឹកស៊ីច្រើនដោយសារមានវិបិត្តផ្លូវចិត្តខ្លះៗពីការងារអស់ទាំងហ្នឹងក្រោយពីការស្តីបន្ទោសអោយខ្លះហើយមានការល្បួងពីខាងក្រៅខ្លះហើយកាលហ្នឹងវាដូចនៅមានភាពវ័យក្មេងវាមិនទាន់ចាស់ចិត្តចាស់គំនិតហាំស!។
កៈ ចាំស។
ខៈ
ក្រោយមកក៏បានបញ្ចាប់ការសិក្សាហ្នឹងក៏បានការជាមួយប្រពន្ធរាល់ថ្ងៃហ្នឹង។ក្រោយមកពួកយើងក៏មានបញ្ហាខ្វះខាតដូចថាមិនទាន់ចាស់ចិត្តចាស់គមនិតខាងការរក្សាលុយកាក់នៅមានការសប្បាយច្រើនហើយមានការទាស់ទែងគ្នាជាច្រើនលើកច្រើនសារហើយម្តងទៅហើយដល់តែពេលបានមួយរយៈកាលមកយើងបានទិញដីមួយនៅខាងពេជ្យនិលហ្នឹងជាមួយនឹងបងប្រុសហើយម្តាយគាត់អីហ្នឹងហើយមានចំនួនប្រាំហិតហ្នឹង។ក្រោយមកដល់ឆ្នាំ២០០៨យើងហ្នឹងកាលទិញមកអស់តែចំនួន៦០០០ដុល្លារជាងហាំស!។
កៈ ចាំស។
ខៈ
ហើយគេអោយតំម្លៃ១០០០០០ដុល្លារហើយពេលគាត់ទាល់គាត់ចង់លក់តែដល់ពេលបានដោះស្រាយបានពីកន្លែងផ្សេងហ្នឹងហើយគាត់លែងចង់លក់ពីកន្លែងហ្នឹងវិញ។ហើយបងមានវិបិត្តមួយដោយសារនឹកតូចចិត្តដោយយើងជាប្អូនគេហើយអត់មានសិទ្ធហាំស!ហើយយើងគិតថាហេតុអីប៉ុន្នឹងគេមិនលក់ដោយសារគេមានតែយើងអត់។

កៈ ហ្នឹងហើយ។
ខៈ
ហើយយើងក៏មិនបានគិតដិតដល់បើយើងគិតអត់ដល់យើងក៏បានគិតខុសផ្លូវជាច្រើនដង។ ក្រោយមកបានភ្ជាប់កូនស្រីមួយទៀតគឺធពណ៏ហ្នឹងបានហើយបងបានបែគគ្នាទៀតបងបានទៅធ្វើការស៊ីឈ្នួលគេហើយបានធ្វើការសន្តិសុខអញ្ចឹងទៅហើយអស់ពីធ្វើការជាសន្តិសុខទៅបងបានរកកន្លែងគុបពីមួយនៅខាងមុខបៀលប្រាយហ៎ស!។
កៈ ចាស។
ខៈ
ធ្វើហ្នឹងជាច្រើនឆ្នាំក្រោយមកថៅកែគាត់រីកចំរើនគាត់បានពង្រីកសាខាមកនៅអូរបែកក្អមណោះ!ហើយបងបានមកនៅអូរបែកក្អមហ្នឹងទៀតបងបានចេះទាក់ទងតាមលេខទូសព្ទអីអញ្ចឹងទៅហើយបងប្រុស អ៊ុក សុផល ហ្នឹងគាត់ជាប្រធានស្តេករសល់ថ្ងៃហ្នឹងគាត់បានផ្សះផ្សារដោយនាំកូនស្រីបងទាំងពីរហ្នឹងក៏បានផ្សះផ្សារអោយបងទាំងពីរបានត្រូវរ៉ូវគ្នាវិញ។ហើយបងក៏បានត្រូវទៅក៏ចេះតែផ្ញើរលុយផ្ញើរកាក់មកអោយគាត់ទៅ
ក្រោយមកបានបងគិតថាចង់មករកស៊ីខ្លួនអែងវិញហើយឈប់ពីកន្លែងធ្វើការមក។
កៈ ចាស។
ខៈ
ធ្វើការខ្លួនអែងលក់ដូរអញ្ចឹងទៅ។ដល់តែមានការល្បែងធម្មតាលក់ដូរក្នុងផ្សារអញ្ចឹងទៅចេះតែមានពួកម៉ាកច្រើនហា៎ស។
កៈ ចាស។
ខៈ
មានការផឹកស៊ីអត់ចេះគិតក្នុងការពិចារណាក្នុងការទុកដាក់នៅទ្រព្យសម្បត្តិបានសប្បាយមួយភ្លែតៗអត់មានការរីកចំរើនដ៏អញ្ចឹងទៅមានការទាស់ទែងគ្នាដោយសារខ្វះខាតហើយប្រពន្ធគាត់ពិបាកចិត្តគាត់ខ្លាំងទៅហើយយើងឯណោះដឹងតែការសប្បាយតែការនេះ..អត់យល់ពីចិត្តគេតែយល់ៗតែពីស្វាងស្រាតែពេលញុំចូលទោយើងអត់បានគិតដោយសារចេះតែស្រវឹងទៅខឹងមួយប្រ៉ាវៗក្រែងលោវាចេញទៅក្រៅអីអញ្ចឹងទៅដល់តែពេលចាយអស់មួយរយះអញ្ចឹងទៅបានមានការអាណិតអាសូគេ។អត់ហ៊ានមកផ្ទះរកការងារធ្វើរហូតបានទិញម៉ូតូទិអីអញ្ចឹងទៅ។មានការល្បែងទៀតអូ!មួយជីវិតនេះព្រះអោយស្គាល់អស់។
កៈ មានបទពិសោធ៍ច្រើន។
ខៈ
ច្រើនណាស់ហើយដឹងដែរថាអាហ្នឹងវាខុសប៉ុន្តែគឺថាមួយភ្លែតៗហ្នឹងធ្វើអោយយើងបាត់នៅអារម្មណ៍ថាសោកស្តាយខ្វះខាតដល់គ្រួសារអត់មាននឹងឃើញ។ប៉ុន្តែដូចថាទ្រង់អោយយើងស្គាល់នៅអ្វីដែឡពិបាកវេទនាអោយអស់អញ្ចឹងហា៎ស។
កៈ ចាស។

ខ៖
បានទ្រព្យសម្បត្តិហើយមានការល្បួងយកទៅបញ្ចាំទាំងអស់ហើយសូម្បីតែគេអត់មានអីសោះគេអោយយើង..អត្តសញ្ញាបត់យើងហ្នឹងក៏ដាក់ម៉ូតូអោយគេដែរហើយដល់តែហើយទៅគេអត់មានការដោះស្រាយដល់យើងហើយយើងក៏អត់មានអីសំអាងត្រូវយកមកវិញក៏ចេះតែរកពីម្នាក់ទៅម្នាក់ៗហើយមានអាមួយនោះវាខូចវាចង់យកក្រដាសបញ្ចាំហ្នឹងទៅលោះម៉ូតូហ្នឹងយកទៀតប៉ុន្តែនេះវាជារបស់យើងគឺអត់បានគេយកអត់បាន។ហើយវាក៏បាននាំបងទៅដល់ស្ពឹងណោះលក់នៅក្នុងផ្ទះសំណាក់ហ្នឹងទៀតអូ!វេទនាខ្លាំងណាស់។
ក៖ លក់អីគេ?
ខ៖
ដូចយកបងយកទៅព្រាត់ចោលអញ្ចឹងហាស!ហើយវាបោកបងយកអាក្រដាសបញ្ចាំម៉ូតូហ្នឹងបើម្បីប្រុងដោះយកម៉ូតូចេញទៅលក់កន្លែងផ្សេងទៅណាស!ទៅរកអ្នកមកលោះម៉ូតូហ្នឹងអញ្ចឹងទៅណាស!ហើយដល់ហើយទៅវាអត់បានព្រោះបងបានប្រាប់នៅកន្លែងបញ្ចាំហ្នឹងហើយថាក្រៅពីខ្ញុំអត់មានអោយពីណាយកទេ។ហើយបងណោះគេទុកចោលហ្នឹងគេជិះមកបាត់មក។ហើយវាអស់កំលាំងព្រោះអត់មានអាហារអីគ្រប់គ្រាន់មកផងនោះហើយដេកនោះវាចូលជិតរយះពេលពីរថ្ងៃហើយមួយយប់ៗហើយល្ងាចឡើងដក់ម៉ោងនួនម៉ោងប្រាំល្ងាចទៀតវាចូលពីរថ្ងៃរបស់គេហើយ
មានតែការនិយាយត្រង់ជាមួយគេដោយសារបងត្រូវគេបោកអញ្ចឹងទៅចំផ្ទះសំណាក់ហ្នឹងគេស្រួលទៀត។
ក៖ចាស។
ខ៖ គាត់ជាជំទាវដែរគាត់ហ្នឹង។
ក៖ ពូនិយាយប្រាប់គេត្រង់ម្តងពីហេតុការណ៍ដែរកើតឡើង?
ខ៖ ហ្នឹងពីហេតុការណ៍ហ្នឹងទៅ បងចុះមកដោយសារសួរគេថា “បងម្នាក់ដែរចុះមកមិញហ្នឹងមានប្រចាំក្រដាសផ្ញើរក្រដាសបញ្ចាំម៉ូតូនៅបងអែងទេមិញ? ព្រោះគេប្រាប់ខ្ញុំថាអញ្ចឹង” ហើយគេថា “អត់មានទេបង”។ ខ្ញុំធ្លាក់ថ្លើមក្តុកម្តងគិតថាគេទៅយកម៉ូតូហ្នឹងបាត់ហើយមើលទៅ។
ក៖ ម៉េចបានក្រដាសបញ្ចាំហ្នឹងទៅនៅលើដៃគាត់?
ខ៖
ចាំមើលអញ្ចេក!វាហ្នឹងវាថាអី....ហើយបងដូចជាទុកចិត្តមួយស្លុយៗដែរដូចមិនដឹងជាយ៉ាងម៉េច?ហើយបាននឹកឃើញខ្លួនអែង។ក្រដាសម៉ូតូហ្នឹងហេតុអីបានអោយគេ?ហើយគេគ្រាន់តែនិយាយថាពេលគេទៅហ្នឹងគេទៅយកម៉ូតូប្អូនគេហ្នឹងយកមកបញ្ចាំហើយយកលុយមកលោះម៉ូតូយើងចេញមកវិញ។ដោយការជឿថានឹងការបារម្មណ៍អោយធ្វើយ៉ាងម៉េចបានម៉ូតូចេញហាស!យើងអត់បានគិតដិតដល់ដែរពេលហ្នឹង។យកម៉ូតូចេញមកគាត់បានអីទាំងអស់គឺមានតែការបោកល្បួងលោងលោមយើងយកម៉ូតូហ្នឹងពីយើងក៏ប៉ុន្តែវាអត់បានសំរេចទេវាគេចបងរហូត។ហើយវាយកទូរសព្ទ័អាទូរសព្ទ័...ហើយនាឡិការក៏វាយកទៅបញ្ចាំថាធ្វើម៉េច

អោយបានគេដោះស្រាយម៉ូតូហ្នឹងមកវិញហាស!មានគ្រប់ល្បិចទាំងអស់សូម្បីតែស្បែកជើងពេលដេកយប់ក៏វាលួចបាត់អស់ទៀតអូ!វេទនាណាស់។អញ្ចឹងបានក្រោយមក....។
កៈ អញ្ចឹងបងដោះស្រាយជាមួយផ្ទះសំណាក់គេយ៉ាងម៉េច?
ខៈ
អូ!គាត់មានគុណធម៌ខ្ពស់ដោយសារថាគាត់អាណិតយើងព្រោះក្នុងនាមយើងជាជនរងគ្រោះមួយដែរត្រូវបានគេបោកហ្នឹងហើយណាមួយយើងវាអត់មានអីក្នុងខ្លួនជាសំអាងផងពេលហ្នឹងយើងមានតែក្រដាសនឹងអត្តសញ្ញាបត័យើងមួយអាអត់ហ៊ីនហ៉ស។
កៈ ចាស។
ខៈ
ពេលហ្នឹងដូជាយ៉ាងម៉េចទេ?យើងសសេរប្រវិត្តរូបអោយគេទៅហើយគេចុះនៅអាកន្លែងកិច្ចសន្យាគេយ៉ាងម៉េចទេ...ដាក់នៅហ្នឹងទៅហើយគេអោយបងមក។ដូចជាគាត់ចិត្តល្អមែនទែន!ចាំមើលណា...គាត់អោយអន្សមពេលទៅដល់ភ្លាមគាត់អោយអន្សមញុំអោយអន្សមញុំហើយគេងៗដល់ហើយប្រហែលជារយះពេលដែលវាបោកចេញមកខាងក្រៅ
ពេលដែលវាបោកស្អែកឡើងចេញមកបាត់ហ្នឹង
អស់កំលាំងអាលីងហើយគាត់នៅផ្តល់អន្សមមួយមកទៀត។អូ!បងភ្លេចប្រាប់អាកន្លែងគេយកទៅបញ្ចាំកន្លែងល្បែងមួយហ្នឹង!គឺបងដាច់បាយចូលរយះពេលបីបួនថ្ងៃបួនថ្ងៃហើយ...ដូចជាមានការបំផុសគំនិតពីព្រះមកអោយបងគឺបងបានអធិដ្ឋានព្រោះកាលហ្នឹងបងធ្លាប់បានទៅព្រះវិហារពេលបងអត់ទាន់បែកពីប្រពន្ធបង
បងផលគាត់ធ្លាប់បាននាំមកព្រះវិហារអីអញ្ចឹងហាស!ហើយប្រាប់ពីអារឿងការអធិដ្ឋានហ្នឹងហើយបងមិនដឹងជានឹកឃើញយ៉ាងម៉េចបងអធិដ្ឋានទៅព្រះគ្រីស្ទហើយពេលហ្នឹងបងបានអធិដ្ឋានហើយអញ្ចឹងទៅដូចជាព្រះឆ្លើយតបមកបងអញ្ចឹង
គឺអោយបងមកកន្លែងបញ្ចាំម៉ូតូចង់ដោះហើយធ្វើយ៉ាងម៉េចអោយបានលុយមកផ្ទះ
ថែមគេ៥០ដុល្លារក៏គេអត់ថែម២០ដុល្លារក៏គេអត់អឹម!អត់ៗដើរមកពួកម៉ូតូឌុបហ្នឹងគេឌុបអត់យកលុយទៀតហើយគេអោយម្នាក់៥០០រៀលអូយ!វេទនាណាស់(ខ្ញុំគិតថាគួរតែបញ្ឈប់វាចោលដែរ)។ហើយគេអោយមកក៏បានជិះអាឡានក្រុងយើងហ្នឹង។
កៈ គេអង្គៀសលុយអោយហាស?
ខៈ
ម្នាក់៥០០រៀលហើយបានតែ១៥០០រៀលគត់បានេជិះឡានក្រុងមកដល់តាខ្មៅហ្នឹងហើយបានមកដល់រកផ្ទះពួកម៉ាកមួយហើយបានគេតេទៅរកបងថ្លៃមួយទៀតដែលគាត់លក់ផ្លែឈើហ្នឹងក៏គាត់បានមកយកមក។ក្រោយមកគាត់ក៏បាននិយាយថាឥលូវគាត់មិនយកទោសបីយអីទេគាត់ចង់អោយយើងចូលផ្ទះសំបែងវិញទៅ។ហើយបងថាអត់ទាន់ចូលទេធ្វើយ៉ាងម៉េចយកម៉ូតូអោយបានវិញសិនព្រោះអីខ្ញុំអស់ពីខ្លួនដែរហើយខ្ញុំបានចាយលុយកាក់អស់ពីខ្លួនហើយអញ្ចឹងត្រូវមានម៉ូតូហើយម៉ូតូហ្នឹងខ្ញុំធ្វើការទើបបានៗយកម៉ូតូហ្នឹងមកវិញហើយឥលូវអត់មានអាហ្នឹងចូលផ្ទះធ្វើម៉េច...បន្ទាប់មកបានទិញបានវិញ។កុំពយមកគាត់អត់ព្រមគាត់ដឹងតែដឹកយកទៅយកមកដល់ផ្ទះមកប្រឈរមុខគ្នា

ហើយក្រោយមកនិយាយអត់ទាន់ដឹងបានស្រុះស្រួលគ្នាទៀតជាមួយគ្រួសារហើយប្រពន្ធខ្ញុំគាត់អត់សូវនិយាយបងថ្លៃនឹងឪពុកគាត់ខឹងខ្លាំងណាស់ព្រោះវាច្រើនដងហើយបងអត់មានការប្រែចិត្ត
ក្រោយមកបងបានចេញទៅផ្ទះបងមួយគាត់នៅក្រោយភូមិជារាប់អានជាបងធម៍មួយដែរជាអ្នកហូបចុកគ្រឿងស្រវឹងខ្លាំងដែរប៉ុន្តែគាត់បានប្រែចិត្តដោយបន្ថយនៅការហូបចុកហើយមានការរកស៊ីជាមួយប្រពន្ធវិញទៅ។
កៈ ចាំស។
ខៈ
ដ៏ហើយគេធ្វើផ្ទះធ្វើអីអញ្ចឹងទៅដ៏ហើយបងតកគំរូរគេទៅស្តាប់នៅការណែនាំរបស់គេបងក៏បានចូលផ្ទះវិញហើយ។
កៈ ការហ្នឹងកើតឡើងក្នុងឆ្នាំណាដែរបង?
ខៈ ឥលូវៗនៀក។
កៈ ឆ្នាំ២០១៧ហាំស?
ខៈ ហ្នឹងហើយក្នុងឆ្នាំ២០១៧នៀក។មុនបងចូលជ្រមុជទឹកហ្នឹង។
កៈ ចាំស។
ខៈ
ពេលហើយទៅបងហ្នឹងគាត់បានយកបងទៅនៅផ្ទះគាត់នៅមុខពេទ្យស្សីហ្នឹងនៅផ្ទះខាងឪពុកក្មេកគាត់នៅជាមួយគាត់ចូលរយះពេលកន្លះខែមួយខែ។ហើយដូចយកយើងទៅពង្រឹងចិត្តយើងហាំស!អោយមានចិត្តស្ងប់ហើយទៅគាត់បានអោយបងទៅព្រះវិហារអញ្ចឹងទៅនៅថ្ងៃអាទិត្យៗហ្នឹងទៅដល់អោយយើងមានអារម្មណ៍មួយថាអោយយើងប្រែចិត្តខ្លះៗទៅគាត់ក៏បានអោយមកផ្ទះសំបែងហើយសមរបសំរួលគ្នាហើយទៅព្រះវិហារទាំងអស់គ្នាមានការបង្រៀនពីសីស្ទើរខ្លាហើយនឹងសីស្ទើរមួយទៀត
បង្រៀនក្រោយមកពួកយើងបានចេះដឹងជាច្រើនហើយមានការប្រែចិត្តទាំងអស់គ្នាដោយបានកំណត់ពេលវេលាជ្រមុជទឹកដល់ពេលជ្រមុជទឹកហ្នឹងមានការល្បួងមួយដោយយើងអត់ទាន់បានមានសេចក្តីជំនឿខ្លាំង
យើងបានជួបកាតល្បួងមួយគឺការសាកល្បងការផឹកស៊ីទៀតពេលហ្នឹងបងមានគ្រោះថ្នាក់ជាខ្លាំងដោយប្រហែលជាទ្រង់...គេហៅថាការប្រដៅហាំស!ការដាក់ទាន់កម្មដោយមានរបួសជាខ្លាំងដោយមានការបាក់ឆ្អឹងជំនីហើយនឹងសន្លប់។
កៈ កើតអីដែរបងបង?
ខៈ ពេលហ្នឹងបងផឹកស៊ីដោយការតាំងពីប្រពន្ធចេញទៅខ្ញុំជិះម៉ូតូមកជ្រុះសោរ។ដល់ពេលចូលកន្លែងក្មេងស្ទាវច្រើនហាំស!វាជ្រុះសោរដល់ពេលសួរនាំគេរឿងសោរហ្នឹងទៅមានអាបងធំគេចូលមកជិះចុះមកពីក្រៅមកក្នុងផ្លូវលំហ្នឹងទៅ
គេឈប់មកគេអត់មានសួរនាំអីច្រើនទេហើយគេអត់មានទាក់ទងអីជាមួយនឹងបងទេតែគេបញ្ជាក្មេងគេហ្នឹងអោយមកវៃបងមិនអោយគេវៃបងក៏តដៃជាមួយគ្នាទៅតដោយការច្រានពួ

កគេចេញហើយបងក៏ដើរចូលទៅមេហ្នឹងហើយមេហ្នឹងដូចវាខ្លាចដែរហើយវាបានរត់ចូលទោក្នុងវិញចូលក្នុងហើយវាបាននាំគ្នាច្រើនហើយវាយកដំថ្មផងមកគប់ខុសៗទៅហ្នឹងហើយយកអាឈើយកមកដេញបុកអើយ!ពេលហ្នឹងបងអត់ទាន់រត់ទៅឆ្វាយដៃរខ្លាចវាយកម៉ូតូ(ពេលហ្នឹងបងបានដោះម៉ូតូមករកស៊ីវិញហើយ)។
កៈ ចាំស។
ខៈ
ដេញបុកៗវាពួយអាឈើហ្នឹងមកខុសទៅបងចាប់អាឈើហ្នឹងបានដេញពួកវារត់ទៅវិញស្របថ៥.៦នាក់ហ្នឹងទៅវារត់ទៅក្នុងបានមួយសន្ទុះបងបោះឈើហ្នឹងចោលស្រាប់តែបងរកយកម៉ូតូចេញមកវាចេញមកទៀតស្រែកសន្លុតមានស្នឹៗច្រើនណាស់
ហើយបងនឹកគិតថាអឺម!ចោលម៉ូតូហ្នឹងម្ទងទៅបើវាយកក៏យកទៅ
តែដល់តែពេលរត់ៗក៏រត់មិនរួចហើយរត់ហ្នឹងកន្លែងតែមើលវាព្រោះខ្លាចវាគប់យើងត្រូវហាំស!ក៏រត់ថយបែបមកក្រោយហើយខ្ញុំជំពប់ជើងដួលវាដាក់ពីក្រោយមក
ត្រូវចង្កេះឡើងជាំបុកនឹងឈើឆ្អឹងជំនីបាក់ហើយបងសន្លប់ទៅ។ហើយគេថាបានប្រហែលជាប៉ុន្មាននាទីប្រហែលជាបីបួននាទីប៉ូលីសមកដល់ដៃរដូចទ្រង់មានការប្រដៅយើងមិនអោយបាត់បង់ជីវិត។
ហើយគេថាភាគច្រើនពួកវាតែងតែមានកាំបិតមានអីហាំស!តែពេលហ្នឹងដូចអត់មានអត់មានកាំបិតមានអីបើពេលហ្នឹងមានកាំបិតមានដាវដូចរាល់ដងវិញសុះអស់ហើយនឹងបាត់បង់ជីវិត។ពេលទៅដល់ហើយប៉ូលីសហ្នឹងបានយកបងទៅពេទ្យកាល់ឡាម៉ែតមានការធ្លាក់ឈាមខ្មៅច្រើនដោយការវាវៃគប់យើងច្រើនហាំស!។
កៈ ចាំស។
ខៈ
ហើយយើងបានយកទៅព្យាបាលនៅបន្ទប់រីអាយភីមួយដោយការជួយជាខ្លាំងពីបងប្រុសទីពីររបស់បងគាត់បានជាជំហរមួយដ៏រឹងមាំក្នុងការជាសំអាងនៅពេទ្យហើយក្រោយមកបងថ្លៃសុផលហ្នឹងគាត់បានដោះស្រាយនៅជំនួយហ្នឹងបានមកពីព្រះវិហារហើយហ្នឹងលុយគាត់ខ្លះទៀតគិតទៅរយះពេល៦យប់៧យប់ហ្នឹងវាអស់ជាងមួយពាន់ប្រាំបីរយដុល្លារ។
កៈ អស់ច្រើនដែរ។
ខៈ
ពេលហ្នឹងបងមានការតាំងចិត្តជាច្រើនហើយមានការប្រែចិត្តដោយការប្រៀនប្រដៅដោយការវៃពីគេជាច្រើន
ហ្នឹងជាអំពើបាបមួយដ៏ធ្ងន់ធ្ងរដែលយើងមានការរៀនសូត្រពីព្រះបញ្ញត្តិហើយយើងបានរមើសនឹងរំលងនៅច្បាប់របស់ទ្រង់នេះជាអំពើបាបមួយដ៏ធ្ងន់ហើយក្រោយមកយើងបានយល់ដឹងយើងបានប្រែចិត្តរហូតមកដល់សព្វថ្ងៃ
សូម្បីតែការជក់បារីក៏យើងផ្តាច់ហើយផ្នែកសុខភាពច្បាប់សុខភាពយើងបានរក្សារដោយការមឹងម៉ាត់ជាច្រើនសូម្បីតែពេលគេជក់បារីក៏យើងអត់មានការហិតក្លិនរបស់គេដែរ។ដោយការការរក្សារនៅសុខភាពល្អហើយដើម្បីអោយព្រះវិញ្ញាណគង់នៅជាមួយយើង។យើងបាន

រក្សាភាពស្អាតស្អំជាច្រើនបន្ទាប់មកយើងបានផ្តល់នៅសុភមង្គលដល់ក្រុមគ្រួសររហូតមកដល់រាល់ថ្ងៃតែប្រហែលជាមិនបានជាមានបានដូចគេឯង។
កៈ មិនហូបហារពេកតែមួយល្មមគ្រប់គ្រាន់។
ខៈ
បាទមួយល្មមគ្រប់គ្រាន់ជាមួយគ្រួសារហើយមានភាពសុខសប្បាយជាងពីមុនជាច្រើនដោយសារយើងមានការយល់ដឹងពីដំណឹងល្អរបស់ព្រះ។
កៈ ចាំស។
ខៈ
ហើយនេះទឹមតែកូនទីបួនត្រឹមបងហ្នឹងហើយចូលដល់កូនទីប្រាំគឺប្អូនស្រីគាត់មានអាយុ៣៥ឆ្នាំហើយប្រហែឡ៣៤,៣៥ឆ្នាំហើយ គាត់អាយុដំនាលប្រពន្ធរបស់បងដែរ។
កៈ ចាំស!គាត់ឈ្មោះអីគេ?
ខៈ ឈ្មោះ សួន តែម
រាល់ថ្ងៃគេមានប្រកបមុខរបរមួយលក់ដូរនៅជំណាក់ស្រុកខេត្តកំពង់ចាមនៅជាយក្រុងគេហ្នឹងគឺគេលក់...គាត់មានការពិនប្រសព្វខាងម្ហូបអាហារដូចបងដែរគឺគេលក់សាច់គោអាំងលក់ជំឡូងអាំងនិយាយរួមងទៅលក់ស្អីៗគេចេះច្រើនណាស់គេធ្លាប់ធ្វើជាចុងភៅនៅកុលាបព្រៃគលៀបហាំស។
កៈ ចាំស។
ខៈ
អញ្ចឹងគាត់ចេះច្រើនរបស់គាត់ក្នុងការលក់ដូរអញ្ចឹងគាត់នាំប្តីគាត់។ហើយប្តីគាត់ហ្នឹងក៏ជក់ខ្លាំងដែរតែឥលូវគាត់នៅតែជក់តែយើងមិនអាចណែនាំបង្រៀនគាំត់បានដោយសារតែយើងគ្មានបានផ្តល់ជាដុំកំភួនអ្វីដល់គេបើនិយាយទៅ។
កៈ ចាំស។
ខៈ
ប៉ុន្តែគ្រួសារគេនិយាយស្តាប់គ្នាដែរមិនសូវប្រឆាំងគ្នាទេយើងគេរកស៊ីមានបានជាងបង។អឹម!ដោយសារគេខំប្រឹងរកហើយគេអត់មានការផឹកស៊ីចោលដូចបងចំណាយចោលរយៈពេល១០ឆ្នាំអត់មានការសន្សំសំចៃ
មានការសន្សំសំចៃមិនបាន...មិនបានជួបព្រះទៀតទោះមានក៏យើងអត់ជឿដែរពេលហ្នឹង។
កៈ អញ្ចឹង?
ខៈ
អត់ដែលស្គាល់ព្រះទេ។ហើយកូនទីប្រាំមួយគឺកូនប្រុសគាត់ជាអ្នកតស៊ូមួយដែរគាត់បានបំបួសនៅមុខភ្លើងហើយគាត់បានបួសជាច្រើនវស្សារបស់គាត់ដែរ
គាត់កើតឆ្នាំឆ្លូវអាយុគាត់ឆ្នាំឆ្លូវអាយុគាត់ដូចជា៣១ហើយណោះ?ឆ្នាំឆ្លូវ។
កៈ គាត់ឈ្មោះអីដែរបង?
ខៈ សួន ឈាង។
កៈ សួន ឈាង។

ខ៖
គាត់សំណាក់ប្រទេសមិនមែនសំណាក់ស្រុកសំណាក់ប្រទេសហ្នឹងសំណាក់ចូលជិត១០ឆ្នាំរបស់គាត់ហើយ!១០ឆ្នាំហើយ។ក្រោយមកឥលូវដូចគាត់...ប្រាក់ខែនៅខាងម៉ាឡេគេអត់ឡើងថ្លៃច្រើនតែ៣០០.៤០០ដុល្លារអីអញ្ចឹងទៅហើយគាត់មានជំហរមួយខ្លាំងនៅក្នុងក្រុមគ្រួសារនៅស្រុកព្រោះអីប្អូនៗចេញអស់ហើយគេការអស់ហើយៗមានតែប្អូនហ្នឹងមួយគាត់មិនទាន់មានគ្រួសារដ៏អញ្ចឹងគាត់ត្រូវឧបបមទៅខាងម្ដាយច្រើនហើយជួយប្អូនស្រីបងបន្ទាប់ហ្នឹងពីរនាក់គ្នាគេហ្នឹងគេឧបបមធ្វើផ្ទះធ្វើអីអញ្ចឹងទៅនៅស្រុកឯណោះហ្នឹង។
ក៖ ចាំស។
ខ៖
ហើយឥលូវគេលែងបានទៅខាងម៉ាឡេហ្នឹងវិញហើយគេទៅលក់ង្អែមនៅខាងកពំង់ចាមជាមួយបងស្រីរបស់គេដែរគឺជាប្អូនស្រីបងហ្នឹងគេលក់បង្អែមដាក់លក់តាមរទេះម៉ូតូគេហានឹង។
ក៖ ចាំស។
ខ៖
គេរកបានយ៉ាងអន់ណាស់ក្នុងមួយថ្ងៃគេរកបាន៨០០០០រទៅ១០០០០០រដែរគេរកបានថេររបស់គេ
ដោយគេបានរីកចំរើនអញ្ចឹងបងក៏សប្បាយចិត្តហើយឥលូវគេចង់រកគ្រួសារគេដែរ។ហើយចំនែកប្អូនបន្ទាប់មួយទៀតហ្នឹងប្រុសឥលូវគេកំពង់តែញៀនថ្នាំខ្លាំងណាស់។
ក៖ គាត់អត់ទានមានគ្រួសារទេបងហាស?
ខ៖ មានដែរ។ប៉ុន្តែដោយសារគាត់មិនស្ដាប់បង្គាប់បងបង្គាប់ម៉ែឪ។
ក៖ គាត់ឈ្មោះអីដែរហើយអាយុប៉ុន្មាន?
ខ៖ ឈ្មោះ សួន ឆៃ គាត់អឺ!អាយុគាត់២០ក្រាស់ហើយ។
ក៖ អូ!គាត់នៅក្មេងដែរអញ្ចឹង។
ខ៖
នៅក្មេងដែរាំកត់មានកូនមួយទៀតហាស!ហើយពេលការហ្នឹងគឺគាត់អត់ស្ដាប់បង្គាប់បងហើយនឹងបងប្រុសឃាច្រើនដែលគាត់ជាចាស់ទុំហ្នឹងគាត់ជំនះ
ហើយបងបានប្រាប់គាត់ថាបងមានបទពិសោធ៍ដោយការយកប្រពន្ធនៅក្មេងខ្ចីហើយបងមិនអាចថាមិនជួយទេតែបងបានប្រាប់ប្អូនមុនពេលប្អូនយកប្រពន្ធយកអី!បងបានប្រាប់ហើយអោយមើលគំរូររបស់បង តើបងរីកចំរើនអី?
បងចង់អោយប្អូនមានការចាស់ចិត្តចាស់គំនិតក្នុងការរកស៊ីក្នុងការរកការងារធ្វើចិញ្ចឹមជីវិតអោយរឹងមាំសិន។ហើយខាងគ្រួសារប្អូនអត់ស្រួលដែរព្រោះគាត់ខាងគ្រួសាររបស់ប្អូនគាត់ស្លាប់ទៅហើយគេអត់បានស្ដាប់គេជំនះ។ពេលគាត់ការហើយអីហើយហ្នឹងគាត់បានទៅរអ៊ូរនាំទុក្ខសោកដាក់ម៉ែឯណោះ
ហើយម៉ែខ្ញុំគាត់ចិត្តទន់គាត់ដឹងតែយំសោកអញ្ចឹងទៅ។គាត់បានប្រាប់បងបានប្រាប់អីថា...ហើយពេលហ្នឹងបងអត់ទាន់បានផ្ដាច់ការផឹកស៊ីទេ។
ក៖ ចាំស។

ខ៖
បងទៅស្រាប់តែពេលហ្នឹងគេស្រាប់តែរករឿងដែរក្រោយមកមានគេអ្នកនៅក្នុងភូមិហ្នឹងគេប្រាប់បងថាអូ!បងអើយៗវាតែប៉ុន្នឹងតែវាមកវាយំត្អូចត្អែរថាតែរឿងអត់មានអ្នកជួយវាហ្នឹង។ ហើយបងបានខឹងវាខ្លាំងណាស់ហើយពេលហ្នឹងបងបានវៃវាដល់បាក់ធ្មេញ
បាទ!វៃហ្នឹងដៃដល់បាក់ធ្មេញបងខឹងពេលហ្នឹងខ្លាំងណាស់អូ!ដល់ចង់សំលាប់វាចោលទៀតដកឈើអារបង្គងរបស់បងប្រុសហ្នឹងដេញវៃហើយអាមិត្តភក្តិបងប្អូនគេហ្នឹងសែងរត់ពីបងទៅ ហើយមានអ្នកខ្លះចាប់ឃាត់បងពេលហ្នឹងខ្មាស់គេក៏ខ្មាស់គេហើយខឹងក៏ខឹងតែមិនដឹងជាធ្វើយ៉ាងម៉េចក្រោយមកវាអត់ប្រែខ្លួនប្រែប្រាណប្រែចិត្តវាមកផ្ទះបងវាយកទូរសព្ទ័បងពេលវាមកហើយបងអត់ដឹង
ពេលវាមកហៅវាដេកហ្នឹងផ្ទះហ្នឹងទៅហើយអោយវាដូចថាអោយវាធ្វើការបែកញើសចេញអាជាតិពុលហ្នឹងវាក៏អត់ជួយធ្វើអីអញ្ចឹងទៅ
ហើយបងក៏អត់ខឹងអត់សម្បាអីទេនៅអោយវាដេកហ្នឹងនៅវានៅស្រួលខ្លួនមានកំលាំងវាជាមនុស្សមានសារធាតុញៀនមិនបានស៊ីចុកអីជាច្រើនថ្ងៃ។ជិះម៉ូតូឌុបវាមកមានលុយអោយវាឯណាអញ្ចឹងវាមកពឹងបងហើយបងកំពុងតែខ្វះខាត
និយាយរួមសូម្បីតែពីរបីម៉ឺនជូនកាលមិនមានផងចំពេលដែលយើងចាយហើយណាមួយមិនចង់អោយជាច្រើនដងពេកហាស!អោយវាដឹងក៏ប៉ុន្តែបើយើងមិនអោយវាគ្មានអ្នកអោយវា។អញ្ចឹងខ្ញុំបានទៅខ្ចីលុយបងយកទោអោយវា។
ក៖ ចាស។
ខ៖
អោយគេទៅហើយទៅវាមកដេកនៅទីនេះជាច្រើនថ្ងៃ។ហើយអត់ដឹងទេដល់តែពេលវាជិតទៅវិញបានជាងមួយគេមកពីស្រុកដែរគាត់ដេកនៅផ្ទះបងនៅខាងលិចហ្នឹងគាត់បានប្រាប់ថាវាបានយកទូរសព្ទ័គេនៅ...ទូរសព្ទ័ក្មួយគេ។ហើយប្រាប់អោយវាទៅវិញអោយវាទៅធ្វើការនៅហ្នឹងទៅអោយវាធ្វើមួយថ្ងៃបាន៥០០០រអីចេះតែអោយវាធ្វើទៅអោយវាបែកញើសទៅម៉េចៗបងបង្កើតអាជីវកម្មអីចេញទៅអោយវាជួយតែវាអត់ប្រែវាអត់ស្តាប់វាឃើញតែទ្រព្យមួយភ្លែតៗហើយទ្រព្យហ្នឹងជាទ្រព្យមិនល្អគឺវាម៉ូតូរបស់គេហើយម៉ែងណោះសងគេជាង២០០ដុល្លារជាងទៀតទៅ។ហើយមានលុយឯណាគាត់បើគាត់ចាស់ហើយហ្នឹងក៏ដោះដូរដីខាងឪពុកអស់មួយភ្លូងទៀតទៅអោយគេទៅ។
ក៖ មានគ្រប់បែបគ្រប់សព្វណោះ?បងប្អូនបង។
ខ៖ ហើយបានប្អូនពៅនេះឈ្មោះ សៀកម៉េង ឈ្មោះ សួន សៀកម៉េងហ្នឹងគាត់ជាប្អូនស្រីពៅគាត់អាយុ២០ឆ្នាំក្រាស់ដែរបន្ទាប់បន្សំគ្នាជាមួយប្អូនហ្នឹងប្អូនទី៧ដែរ។គាត់បានរៀបការ
ហើយពួកខាងចាស់ៗខាងបងហ្នឹង!ពេលហ្នឹងបងដូចអត់ទាន់អីលូតលាស់អីហើយមានការផឹកស៊ីច្រើនអញ្ចឹងគេអត់សូវស្តាប់សម្តីបង។បងហាមគេហ្នឹងមិនទាន់អោយរៀបការទេ។
ក៖ ចាស។

ខ៖
ហើយគេការនៅអាយុ១៩ឆ្នាំហើយខ្ញុំថាគេនៅក្មេងណាស់មិនទាន់អោយការទេតែអត់មានអ្នកស្តាប់ទេ គេបានស្តីបន្ទោសទៀតបងទីមួយហ្នឹងគាត់ស្តីបន្ទោសថា "បើអែងមិនជួយជោកជួយចៃកុំយកជើងរាទឹកគេ"
អឹម!ដល់ពេលប្អូនមានបញ្ហាគាត់អត់មាត់អត់ក៏ទេហើយបងក៏សកអោយគេវិញថា "ម៉េចហើយ?អត់ស្តាប់សំដីអាថោកហ្នឹងវាអញ្ចឹង"
ហើយបងនិយាយដោយការខឹងហើយពេលហ្នឹងបងនិយាយថាអោយគេ
អត់មានអ្នកមាត់ទេហើយម៉ែក៏ចេះតែបៀមទុក្ខខ្លួនគាត់។ដល់ហើយគេបែកផ្លូវគ្នាចែកកូនមួយម្នាក់ព្រោះកូនគេពីរ។
ក៖ ឥលូវគាត់លែងលះគ្នាហើយណេះ?
ខ៖
លែងទៅហើយដល់ឥលូវបានប្តីក្រោយនេះធ្វើការរោងចក្រជាមួយគ្នាហ្នឹងគេមានការស្តាប់បង្គាប់ដែរល្អដែរក្រោយមក។ដូចអស់កម្មរបស់បងដែរ។
ក៖ ចាស។
ខ៖
ហើយគេបានកូនប្រុសមួយទៀត(បានពីរឥលូវមុននោះមួយក្រោយមួយទៅក៏បានពីរហ្នឹង) ឥលូវគេស្រួលដែរប្តីស្តាប់ប្រពន្ធហើយប្រពន្ធស្តាប់ប្តីព្រោះគេនៅមានភាពវ័យក្មេងដែរតែមើលទៅមិនទាន់ជាស្រួលទេក៏ប៉ុន្តែគេស្រលាញ់ប្រពន្ធគេដែរ។
ក៖ ចាស។
ខ៖ អញ្ចឹងបងអត់សូវមានការពិបាកនៅតែប្អូនប្រុសមួយហ្នឹងដោះស្រាយយ៉ាងម៉េចចង់ធ្វើចារិកដូចប្រធានស្តេកដែរប៉ុន្តែមិនដឹងថាធ្វើវិធីណាសំរាប់ប្អូនហ្នឹងអោយកែបាន។
ក៖ អត់អីទេបង្អួនជួយទូន្មានគាត់តិចម្នាក់ៗទៅយូរៗទៅគង់តែគាត់ដឹងខ្លួន។
ខ៖ ឥលូវវយកម៉ូតូហ្នឹងទៅមិនដឹងបានយ៉ាងម៉េចៗវិញទេ។
ក៖ ចាស។
ខ៖ បើនៅម៉ូតូហ្នឹងទៅចេះតែរំដោះគ្រោះវាទៅចេះតែរកស៊ីទៅព្រោះយើងបានសងគេហើយអញ្ចឹងហាស។
ក៖ ចាស។
ខ៖
តែខ្លាចតែវាទៅភ្លឹតភ្លឹនជាមួយអាថ្នាំញៀនហ្នឹងទៅ!ប្រចាំម៉ូតូលក់ម៉ូតូហ្នឹងយកលុយចាយអស់ៗហើយអត់មានអីជាផ្លូវ។
ក៖ និយាយទៅបងប្អូនបងម៉្យាងម្នាក់ណេះ!ប្រុសនឹងស្រី?ចាស!។
ខ៖ ភាគច្រើនបានស្រីហើយប្រុសមួយប្អូនហ្នឹងគ្នាល្អទេចង់អោយគាត់បានប្រពន្ធនៅក្នុងព្រះវិហារហ្នឹងដែរអោយសមនឹងការដែលគាត់ធ្វើល្អ។

ក៖
ចាស!អញ្ចឹងទាក់ទងជាមួយហ្នឹងឪពុកម្ដាយបងវិញតើបងអាចជំរាបបានទេថាម្ដាយបងគាត់ឈ្មោះអីដែរ?
ខ៖ គាត់ឈ្មោះ ប៉ន យៀង
គាត់ជាស្ត្រីមេម៉ាយដែរតលូវដោយសារឪពុកគាត់បានលាចាកលោករយៈពេលជាច្រើនឆ្នាំហើយគាត់ស្លាប់ក្នុងព្រះជន្ម៦៣ឆ្នាំ។
ក៖ ចាស។
ខ៖
គាត់ស្លាប់ហ្នឹងដោយភាពចៃដន្យហើយមិននឹកស្មានដល់។មានជំងឺជាច្រើនដែរធ្វើអោយគាត់វេទនាក្នុងការប្រកិតប្រកោយក្នុងការរស់តែគាត់បានរួចផុតមើលជំងឺជាតែដល់ពេលមកស្លាប់នេះគឺមិនសមគួរណាគាត់ស្លាប់ហើយគោ...ដោយសារគោពីរក្បាលគាត់នៅស្ដាយគាត់នៅចិញ្ចឹមតែនៅពេលហ្នឹងបងៗគាត់អោយលក់គោហ្នឹងទៅកុំនៅចិញ្ចឹមអីព្រោះគាត់ចាស់ហើយណា៎!។
ក៖ ចាស។
ខ៖
គាត់ចាស់គាត់មានមាឌរឹងមាំឯណា!ហើយយើងមិនចង់អោយគាត់មើលគោហ្នឹងហា៎ស! តែគោហ្នឹងគេអោយថ្លៃដែរតែគាត់អត់លក់។គាត់ចេះតែស្ដាយព្រោះគោហ្នឹងមានកូនមានអីក្នុងពោះ
ហើយគាត់ទៅរកស្មៅគោហ្នឹងក្នុងម៉ោងរយៈពេលម៉ោង១២ហ្នឹង(អាហ្នឹងស្ដាប់បានគេនិយាយប្រាប់ហា៎ស!)អឺ!គាត់បានទៅយកស្មៅគោជើងទីពីរហ្នឹងគាត់!ផ្ទះបងប្អូនគាត់នៅកណ្ដាលភូមិហ្នឹងគាត់បានចូលទៅគាត់ហូបនំប័ងបានតិចតួច(គេអោយហ្នឹងជាមួយទឹកតែជាមួយអីអញ្ចឹងទៅ)ហើយក៏បានទៅយកទៅហើយយកមកវិញហ្នឹងក៏បានបណ្ដើរ....ស្ពានហ្នឹងគេធ្វើស្ពានថ្មហា៎ស!ហើយទន្លេអាដៃទន្លហ្នឹងវាគោក....។
ក៖ ចាស។
ខ៖
អញ្ចឹងគេវៃអាកណ្ដាលហ្នឹងទៅដើម្បីកាយអីអោយហូរហា៎ស!អោយវាជ្រៅហ្នឹងហើយគេធ្វើស្ពានឬស្សីមួយសំរាប់ឆ្លងគាត់អ៎!សំរាប់ឆ្លងបណ្ដោះអាសន្នហ្នឹង!ពេលគាត់បណ្ដើរដូចជារអិលជើងរឺក៏យ៉ាងម៉េចទេ!ហើយអាស្ពានហ្នឹងវាអត់មានបង្កាន់ដៃបង្កាន់អីទេ។
ក៖ ចាស។
ខ៖
គាត់ដួលខ្លួនទៅនៅគៀនច្រាំងដែរហើយគេមានកាប់អាដើមប្រេងខ្យល់ប្រហែលម៉ាកួយហ្នឹងនៅច្រងុយៗហ្នឹង
ដួលទៅហើយវាច្រាត់ដៃទៅបុកចំអាឆ្អឹងជំនីពេលហ្នឹងជំងឺ....អ៎!ឧបត្តិហេតុបងហើយហ្នឹងគាត់ហ្នឹងដូចគ្នាប៉ះបាក់ឆ្អឹងជំហៀងជំនីហ្នឹងដូចគ្នា
បងខាងឆ្វេងតែគាត់មិនដឹងជាខាងឆ្វេងខាងស្ដាំតែប៉ះហ្នឹង!ធ្លាយទៅប៉ះសួតទៅសន្លប់ហើ

យយកទៅដល់ពេទ្យសាលាស្រុកហាស!ខាងត្រើយម្ខាងត្រើយខាងលិច ទោដល់ពេទ្យគាតើបានស្លាប់។ហើយចេះជិះចេញពីនេះទៅនៅអត់ទាន់គាត់ទៀតពេល ទៅដល់ពេទ្យគេយកគាត់មកដល់ផ្ទះបាត់។មកដល់ផ្ទះគេរៀបចំគាត់នៅហ្នឹងផ្ទះហើយៗ។
កះ គួរអោយសោកស្តាយណាស់បង។
ខះ
ជំងឺគាត់ដែរខ្លាចភិតភ័យហ្នឹងការរស់មិនចង់រស់នោះបែរជាព្យាបាលជា។ហើយគាត់មាន សាច់មានឈាមជ្រះថ្លាវិញហើយតែបែរទៅជាគាំត់ស្លាប់អញ្ចឹងៗទៅ។
កះ អាណិតគាត់ណាស់ណំ!នៅពេលគាត់ស្លាប់ដោយសារឧបត្តិវហេតុអញ្ចឹង។
ខះ បាទវាមិនសមរម្យ។
កះ និយាយទៅវាចៃដន្យពេកហាស។
ខះ
ចៃដន្យពេក។អ៎!អាហ្នឹងបើនិយាយតាមហោរាគេហាស!មានអ៊ុំមួយគាត់នៅខាងមុខផ្ទះបង ហ្នឹងគាត់បានទោសទាយអោយគាត់ថាឪពុកអែងហាស!បើគាត់បានរស់ដល់អាយុ៦៥ឆ្នាំ គាត់បានអាយុវែងទៀតហើយ
គាត់មើលព្យាបាលជាអស់ហើយហ្នឹងឃើញទេ?តែយើងមិននឹកស្មានថា...អឺម!គាត់បានអា យុវែងវិញហើយលែងអីហើយ។ពេលគាត់អាយុក្នុង៦៣ហ្នឹងហាស!ពេលគាត់ចូល៦២ចូ ល៦៣ឆ្នាំហ្នឹងគាត់ឈឺយកមកពេទ្យនៅស្អាងហ្នឹងហាស!គាត់ដាក់ឧស៊ីហែនអត់ចង់ទាន់ ហាស!ហើយយកមកព្យាបាលទាន់បងទៅកុំដរគាត់រយះពេលមួយអាទិត្យព្យាបាលជាគ្រា ន់បើវិញទៅហើយបងក៏បញ្ជូនគាត់ទៅផ្ទះទៅស្រុកវិញទៅ។បងមករៀនវិញធម្មតាទៅហើ យគាត់ជាដល់អាយុ៦៣ឆ្នាំក្រោយមកគាត់មកស្លាប់ហ្នឹងហេតុការណ៍អញ្ចឹងៗវិញក៏ចេះតែ នៅនឹកគិតស្តាយគាត់។
កះ ចាស!គាត់ឈ្មោះអីដែរបង?
ខះ គាត់ឈ្មោះ សួន អៀវ ហើយគាត់ស្លាប់ហ្នឹងព្រះជន្ម៦៣ឆ្នាំ។
កះ ចាស!បងចាំថ្ងៃខែឆ្នាំកំណើតគាត់ទេ?
ខះ ហើយថ្ងៃខែឆ្នាំកំណើតគាត់គឺបងចាំតែឆ្នាំទេគេដាក់ឆ្នាំពីមុខគឺឆ្នាំ១៩៥៣ៗ។
កះ ចុះឆ្នាំសត្វគាត់តើបងចាំឆ្នាំសត្វគាត់អត់?
ខះ អ៎!ឆ្នាំសត្វគាត់ដូចខាលតែបើយើងដកពីអាហ្នឹងទៅយើងដឹងអាយុគាត់ហាស!ឆ្នាំហ្នឹង។

កះ ចាស។
ខះ ហ្នឹងហើយ។
កះ ហើយគាត់មានទីកន្លែងកំណើតនៅទីណាដែរ?
ខះ ទីកន្លែងកំណើតគាត់នៅក្បាលកោះធំហ្នឹងម្មង ស្រកកំណើតទាំងប្តីទាំងប្រពន្ធគាត់ហ្នឹង។
កះ ចាស!ភូមិអីស្រុកអីខេត្តអីដែរ?
ខះ គឺនៅភូមិក្បាលកោះធំឃុំកោះធំកស្រុកកោះធំខេត្តកណ្តាល។

កៈ ហើយកាលគាត់នៅរស់តើគាំត់ជាប្រភេទមនុស្សយ៉ាងម៉េចដែរបង?
ខៈ
គាត់ជាមនុស្សមានការរាប់អានជាច្រើនពីភូមិមួយទៅភូមិមួយហើយគាត់ដូចធ្លាប់មានប្រវិត្ត
គាត់មួយដូចជាគាត់បានបួសអញ្ចឹងទៅ!ហើយគាត់ជាមនុស្សមានការរាប់អានច្រើន។ហើយ
ការងារគាត់ហ្នឹងគឺគ្មានអីធំដុំទេគឺគាត់ជាអ្នកអារឈើដោយដៃក្នុងការប្រកបរបរចិញ្ចឹមជីវិត
គាត់។
កៈ ចាំស!ចុះម្ដាយបងវិញតើបងដឹងពីថ្ងៃខែឆ្នាំកំណើតគាត់នឹងទីកន្លែងកំណើតគាត់អត់?
ខៈ
ទីកន្លែងកំណើតគាត់នៅក្នុងភូមិជាមួយគ្នាហ្នឹងហើយគាត់...ហើយបងថ្ងៃមួយបងបានទៅ
ស្រង់នៅជីវប្រវិត្តរបស់គាត់ដែរហើយដោយសារតែការធ្វេសប្រហែសរបស់បងអត់បានយ
កនូវការកត់ត្រាហ្នឹងមក
រាល់ថ្ងៃនៅស្រុកហ្នឹងអត់បានយកមកចាំថ្ងៃណាបងទំនេរបងទៅយកមក។
កៈ តែបងដឹងឆ្នាំគាត់កើតទេ?
ខៈ ឆ្នាំគាត់...។
កៈ គាត់ប្រហែលជាប្អូនឪពុកបងប៉ុន្មានឆ្នាំដែរ?
ខៈ
ប្អូនច្រើនដែរប្រហែលជាចូលជិតមួយជួរហើយ។មួយជួរហើយយ៉ាង!គាត់ប្រហែលជា៥០ឆ្នាំ
ក្រាស់ក្បែរ៦០ហើយហ្នឹង គាំត់៥០ឆ្នាំក្រាស់ហើយ។
កៈ តើគាត់នៅរស់សព្វថ្ងៃដែរបង?
ខៈ គាត់នៅរស់សព្វថ្ងៃ។
កៈ តើម្ដាយបងគាត់ជាមនុស្សប្រភេទយ៉ាងម៉េចដែរបង?
ខៈ គាត់ជាមនុស្សមានមនោសញ្ចេតនាខ្លាំងហើយគាត់ជាប្រពន្ធទីពីររបស់ឪពុករបស់បង។
កៈ ចាំស។
ខៈ
ពីមុនបងស្រីគាត់មានកូនបីនាក់ជាមួយនឹងបងៗហ្នឹងបងស្រីគាត់ត្រូវជាបងបង្កើតរបស់គា
ត់ហ្នឹងគាត់បានមានកូនជាមួយឪពុកបងរាល់ថ្ងៃហ្នឹងបានកូនប្រុសបីនាក់ហើយក្រោយមក
គាត់បានស្លាប់ទៅហើយម្ដាយរបស់បងហ្នឹង!លោកយាយបងហ្នឹងគាត់បានអាណិតកូនទាំង
បីហ្នឹងក៏គាត់បានអោយម្ដាយបងហ្នឹងជួយ..ដូចជួយអោយមើលបងអញ្ចឹងហាំស!ដោយការ
អោយរៀបការជាមួយឪពុកបងជាបន្តរទៀតទៅ។ដូចជានៅមើលក្មេងៗដូចបងពីរបីនាក់ប
ងហ្នឹងហាំស!ប្រុសបួនាក់ហ្នឹងអញ្ចឹងទៅម៉ែបងក៏ព្រមហើយបានរៀបការជាមួយគ្នាបានកូន
ក្រោយហ្នឹងចំនួនប្រាំនាក់ទៀតប្រុសបីស្រីពីរ។
កៈ
ចាំស!ចុះបងនៅចាំសាច់រឿងខ្លះដែរទាក់ទងពីឪពុកម្ដាយរបស់បងដែរគាត់ធ្លាប់ប្រាប់ហាំស
!ថាជីវិតរបស់ពួកគាត់កាលនៅពីក្មេងយ៉ាងម៉េចដែរតើបងចាំខ្លះៈទេ?។

ខ៖
បើជីវិតពួកគាត់មុនគាត់ជាជីវិតកសិករមួយហើយជំនាន់បែកហើយគឺបងទាន់ក្នុងជំនាន់បង
កើតហ្នឹងតាំងពីឆ្នាំ៨១(១៩៨១)មករហូតមកដល់បងដឹងក្ដីខ្ទង់១០ឆ្នាំហ្នឹងគឺបងដឹងពីការលំ
បាកជាច្រើនក្នុងការខ្វះខាតគឺពួកបងបានធ្វើស្រែនៅឯឆ្ងាយនៅបឹងឆ្ងាយពីស្រុកនៅឆ្ងាយពី
ភូមិដោយការថ្មើរជើងជូនកាលជិះកង់អាកង់ខ្មែរយើងហ្នឹងពីមុនហ្នឹងអត់មានប្រាំងអត់អីទេ
ឌុបជាមួយម្ដាយអីអញ្ចឹងទៅទៅធ្វើ។ហើយឪពុបងអត់បានទៅធ្វើគាត់នៅអារឈើ
ហើយនៅអារឈើក្នុងភូមិហ្នឹងហើយបងពីនាក់ម្ដាយបានទៅធ្វើស្រូវធ្វើអីទៅកាប់ទន្ទាន់ព្រៃ
ហើយនឹង!អាប្រែកន្រ្ទឹមយើងធ្វើនៅនឹងទឹកហ្នឹងម្ដង!ទឹកត្រឹមជង្គង់ហ្នឹងហើយកាត់ស្មៅគេអា
ស្មៅកន្រ្ទឹមហ្នឹងកាប់គរខ្ពស់ៗហើយជូនកាល....ហើយើងធ្វើអត់បានច្រើនប៉ុន្មានទេដោយ
សារយើងអត់មានកំលាំងធ្វើ។ហើយដីកាលហ្នឹងអត់មានជាដីពីណាទេ
គ្រាន់តែយើងកាប់ទន្រ្ទាន់ជាប្លូងៗទៅហើយធ្វើស្រូវហ្នឹងទៅ។ហើយជូនកាលហ្នឹងទឹកឡើង
មកលិចកណ្ដាប់លិចអីក៏មានដែរ។វេទនាដែរពេលហ្នឹងហើយដោយការធ្វើស្រូវអត់បានហ្នឹ
ងក៏មានដែរជូនកាលដើរសន្សំអាស្រូវគេច្រូតហើយហាស!យកមកបុកដែរលាយពោត។បង
មានពេលមួយបងដាច់បាយក្នុងគ្រួសារដោយសារឪពុកឈើអត់មានលុយច្រើនហើយពួក
យើងនៅរៀនបឋម!មានបងស្រីមួយគាត់ជាក្រមុំចាស់ហើយក្នុងភូមិហ្នឹងគាត់បានអាណិត
ហើយបានឧបថមនូវអាហារដូចជាបាយកកបាយអីហ្នឹងយកទៅហាលទុកហូបហើយនឹង
បាយទាគេអាណិតក៏ចេះតែហៅទៅហូបជាមួយគេ។ហើយពេលព្រឹកឡើងជូនកាលទៅរើ
សស្វាយដែលសត្វចឹងធ្លាក់ហាស!ប្រហែលជាម៉ោងបួនប្រាំភ្លឺនាំគ្នាទៅរកជាមួយយាយ
ទៅរកមកយកមកចិតញុំជាមួយបាយកកក៏មាន។ហើយចាប់គីង្គក់តាមព្រៃពោតហាស!។
ក៖ ចាស។
ខ៖ ខាងកាលហ្នឹងស្រុកបងគេចូលចិត្តដាំនៅចំការពោតជាច្រើន
អូ!មាត់ទន្លេហ្នឹងគឺដាំច្រើនណាស់ហើយពួកយើងដើរចាប់វាតាមគុម្ពពោតបានច្រើនណាស់
បើនិយាយពីការសំលាប់សត្វបើបាបវិញមិនដឹងជាបាបប៉ុន្មានលានតោនទេ
ក្នុងមួយថ្ងៃតូចណាស់ក៏ជិតបាន១០០គីង្គក់ដែរ។អឹម!ហើយក៏អញ្ចឹងទៅក៏វាមានការ..វាទៅ
ការមានលក្ខណះដូចថាវាទៅជាបទពិសោធ៍មួយមួយក្នុងជវិតហើយលែងសូវអីហើយ។
ក៖ ចាស។
ខ៖ ហើយបានក្រោយមកបានម៉ែគាត់ធ្វើកន្ទេលហាស!បងមានអាយុ១០ឆ្នាំ
កាលហ្នឹងលក់គោអស់ហើយបងៗគេការអស់ហើយលក់គោគ្រាន់តែគេការដូស្រូវមកគ្រាន់
តែគេការ អញ្ចឹងទៅគាត់ឧបត្ថមបងគាត់នៅរៀននៅតាខ្មៅហ្នឹង
ហើយបងឯណោះនៅមើលគោ១០ក្បាលក្រៅពីហ្នឹងគេការអស់ហើយ។ហាយគាត់ធ្វើកន្ទេ
លហ្នឹងគាត់ធ្វើហើយយកកន្ទេលជាមួយកង់អត់ប្រាំងដឹកម៉ែមកដល់តាកែវយើងនៀកគេ
ជើងកូនជើងអីយើងនៀកនៅខាងតាកែវ។ធាក់កង់មកហ្នឹង!ជើងធាក់មិនដល់ដីផងហ្នឹងជើង
មួយធាក់ជើងមួយទំលាក់ដល់ដីជើងមួយចំហៀងក៏ចេះតែធាក់ទៅចេះបានមកដល់ដែរ។
ហើយពេលមកដល់អាកន្លែងខ្សាច់ចុះអាផ្លូវគេហ្នឹងមានខ្សាច់ផុសជាន់ហើយបងមានធាក់ក

ង់រួចឯណាចុះបណ្ដើរកង់ទំរាំផុតអាខ្យាច់ហ្នឹងហើយទៅមានគេរាប់អានគេអាណិតអញ្ចឹងហើយយើងសុំគេចូលសំរាកបាយអញ្ចឹងយើងយកកន្ទេលដូរនឹងផ្ទះហ្នឹងដូរយកបាយ។
កៈ ចាំស។
ខៈ
គេអោយបាយសម្លរគេទំនងណាស់ហើយបើអុសគេពូតជាមួយហ្នឹងអាច់គោដុតហើយនឹងសម្លរម្ជូរនំបញ្ចុកគេ។
កៈ ចាំស។
ខៈ អូ!ហើយបងមនចេះហូបអី!ទឹកត្នោតផ្អែមស្រួចហូបបាយទៅ។
កៈ ម៉្យាងដែរជីវិត។
ខៈ ខ្លាំងដែរស្គាល់អាជីវិតលំបាកអញ្ចឹងហើយពេលបានមកដល់កន្លែងស្រួលអូ!វាមិនស្រួលទេគ្រាន់តែថាជីវិតយើងវាស្គាល់ជូរចត់ច្រើន។
កៈ
ចាំស!ហើយចុះឪពុកម្ដាយបងដែរប្រាប់បងរឿងខ្លះៗទាក់ទងពីតាយាយខាងឪពុកក៏ដូចជាតាយាយខាងម្ដាយទេ?
ខៈ អូ!បើប្រវិត្តខាងឪពុកៗគាត់ហ្នឹង។
កៈ ឈ្មោះអីហើយមានអាយុប៉ុន្មាន?
ខៈ អើយ!គាត់ឈ្មោះតា វេ ហ្នឹងអូ!តា សួន ហ្នឹងគាត់កើតក្នុងឆ្នាំ១៩០៦។
កៈ ចាំស។
ខៈ ហើយប្រពន្ធគាត់១៩០៧។
កៈ ប្រពន្ធគាត់ឈ្មោះអីដែរហើយទីកន្លែងកំណើតគាត់នៅទីណា?
ខៈ នៅ!និយាយរួមទៅនៅកោះធំហ្នឹងទាំងអស់ហើយគាត់ឈ្មោះ វេ(សួន វេ) ហើយបើខាងប្រវិត្តម្ដាយឈ្មោះ តាល្អចៗហ្នឹងអឺ!ឈ្មោះ ប៉ុន(តា ប៉ុន) ខាងម្ដាយឪពុករបស់យាយហ្នឹង។
កៈ ចាំស។
ខៈ ចាំតែតាប៉ុនហ្នឹងមួយខាងយាយតែបើប្រពន្ធគាត់នោះអត់ចាំ។មានការកាត់ត្រាដែរតែដូចបងប្រាប់អញ្ចឹងតែភ្លេចយកមកហើយយាយវិញឈ្មោះយាយ សន ហើយប្ដីគាត់ឈ្មោះតាល្អចគាត់បានបែកគ្នាដែរ។
កៈ ចាំស!អញ្ចឹងនៅ...។
ខៈ មិនដឹងជាបែករឺក៏គាត់ស្លាប់តែភ្លេចបាត់ហើយមិនពីពេលកាលគាត់នៅរស់ទេ។
កៈ ចាំស!អញ្ចឹងបងបានដឹងតែប៉ុន្នឹងទេទាក់ទងជាមួយនឹងតាយាយណោះ?
ខៈ
ពីជីវប្រវិត្តហ្នឹងបានតែត្រឹមហ្នឹងប៉ុន្ដែបើចង់ដឹងពីអាយុម្ដាយហ្នឹងទាល់តែបានទៅយកការកាត់ត្រាហ្នឹងមកអាហ្នឹងបានច្បាស់។ដោយគាត់មានប្រវិត្តកំណើតគាត់ច្បាស់លាស់ផងដែរ។

កៈ ចាំស។
ខៈ
តែបើពីតាទួតយើងស្បូនហើយដោយសារគាត់អត់បានចាំសូម្បីតែពួកគាត់ហ្នឹងក៏ពួកគាត់មិនបានទាំងឃើញច្បាស់ផងនៅជំនាន់កាប់សំលាប់។
កៈ ចាំស។
ខៈ
ពីព្រោះអីចាស់ៗអត់មានការកាត់ត្រាដូចជាយើងហ៎ាស!គាត់ចាំដោយខួរក្បាលគាត់ហើយជូនកាលគាត់ចាស់ទៅគាត់គិតពីអាជីវកម្មរឺក៏គិតេពីរបរចិញ្ចឹមជីវិតគាត់ទៅ។គាត់អត់សូវចាំង៍អញ្ចឹងគាត់អត់សូវចាំអត់មានកំណត់ហេតុមួយដែរអាចទុកអោយកូនចៅក្រោយ។
កៈ ចាំស។
ខៈ ដល់ឥលូវយើងមានការកាត់ត្រាអញ្ចឹងទៅស្រួល។
កៈ ចាំស។
ខៈ
តែបងក៏សូមអរគុណដែរពីការសំភាស៍ហ្នឹងព្រោះអានេះជាមរតកសំរាប់កូនរបស់បងនៅពេលក្រោយរឺមួយក៏បងសំរាប់....។
កៈ ចាំស។
ខៈ ការឆែកចង់ដឹងពីប្រវិត្តគ្រួសារដែរ។
កៈ ចាំស!អញ្ចឹងទាក់ទងជាមួយហ្នឹងអាពាហ៍ពិពាហ៍របស់បងវិញតើភរិយាបងគាត់ឈ្មោះអីដែរ?ហើយតើបងចាំពីថ្ងៃខែឆ្នាំកំណើតគាត់នឹងទីកន្លែងកំណើតរបស់គាត់អត់បង?
ខៈ អឺ!គាត់ឈ្មោះ អ៊ុក ធារី។ អឺ!ថ្ងៃខែឆ្នាំកំណើតគាត់ហ្នឹងខាងអឺ!គេកត់ធ្វើអត្តសញ្ញាប័តហ្នឹងវាពិបាកទៀតហ្នឹងហើយគេដាក់ថាថ្ងៃ០១ខែ០៥ឆ្នាំ(៨៤)១៩៨៤។
កៈ ចាំស!អញ្ចឹងបងរៀបអាពាហ៍ពិពាហ៍ហ្នឹងរយៈពេលប៉ុន្មានឆ្នាំហើយបង?
ខៈ អឹម!ការបងរៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ២០០៩ខែ១២,២០០៩។
កៈ បងចាំថ្ងៃទេ?
ខៈ ថ្ងៃហ៎ស?ថ្ងៃ០៩ខែ១២ឆ្នាំ២០១៩ហ៎ាស!២០០៩។
កៈ ចាំស!តាំងពី២០០៩រហូតមកដល់ឥលូវមានរយៈពេល។
ខៈ ១២ហ៎ាស!១៣ឆ្នាំហើយ។
កៈ ១៣ឆ្នាំហើយ។អញ្ចឹងបងមានកូនប៉ុន្មាននាក់ដែរបង?
ខៈ បងមានកូនពីរនាក់ស្រីទាំងពីរ។
កៈ ឈ្មោះអីដែរ?
ខៈ កូនទីមួយឈ្មោះ ឆដា(នីន ឆដា)គាត់មានអាយុ១២ឆ្នាំគាត់រស់នៅក្នុងបន្ទុករបស់បងហើយកូនទីពីរឈ្មោះ នីន ឆពណ៌ គាត់ភេទស្រីដែរគាត់នៅក្នុងបន្ទុកបងដែរ។

កៈ គាត់អាយុប៉ុន្មានបង?
ខៈ គាត់អាយុ៩ឆ្នាំ។
កៈ អាយុ៩ឆ្នាំ។អូ!នៅតូចៗដែរបងណេះ?
ខៈ បាទ។
កៈ
អញ្ចឹងទាក់ទងជាមួយហ្នឹងអាពាហ៍ពិពាហ៍របស់បងតើវាត្រូវបានរៀបចំឡើងដោយឪពុកម្តាយរបស់បងជាអ្នកផ្សំផ្គុំ?រឺក៏បងអឺ!ជួបបងស្រីដោយខ្លួនឯងហើយមានចិត្តស្រលាញ់គាត់នឹងរៀបការដោយខ្លួនអែង?
ខៈ
អឺ!នេះជាការពេញចិត្តរបស់បងផ្ទាល់ដោយការមើលឃើញគាត់ជាមនុស្សល្អ។ហើយការរៀបការហ្នឹងគឺដូចបងបានប្រាប់ពីការណែនាំប្អូនអញ្ចឹងហាស!
កៈ ចាស។
ខៈ
ពេលហ្នឹងដោយសារការឃើញពីគេហើយប្រពន្ធបងល្អក៏មានចិត្តចង់ការដោយថាខ្លាចបាត់បង់គេអញ្ចឹងទៅ។
កៈ ចាស។
ខៈ ហើយណាមួយគេនៅជិតផ្ទះបងស្រាប់(ផ្ទះរបស់បងហាស)។
កៈ ចាស។
ខៈ
ហើយបងចង់នៅជិតបងហាស!ដើម្បីបងប្អូនមកសំណាក់ស្រុកពីរនាក់ហ្នឹងកុំអោយឆ្ងាយពីគ្នាអញ្ចឹងទៅណាស។
កៈ ចាស។
ខៈ
បានជិតគ្នាជួយមើលគ្នាអីអញ្ចឹងទៅហើយបងក៏បានទៅរកគ្រូទាយហាស!កាលហ្នឹងបង...មានអ៊ុំមួយដែលនៅស្រុកហាស!គាត់នៅជិតផ្ទះគាត់ចេះទាយដែរហើយគាត់ថាអោយពួកបងហ្នឹងអត់ទាន់បានត្រូវយកគ្នាទេបើអោយយកគឺគ្រាន់បានត្រឹមតែមួយស៊ីៗអីអញ្ចឹងហាស!។
កៈ ចាស។
ខៈ
ដូចថាអត់ទាន់ជាគូហ្នឹង!ហើយបងក៏ថាហើយបើការក៏ការទៅពួកអែងមិនអីទីគ្រាន់តែថាបានតែកូនមួយហើយមានបញ្ហារហូតដល់ដាច់ក្បាលទៀតក៏មិនលើកលែងអោយគ្នាដែរ។គឺបងចំណាំសម្តីគាត់គឺគាត់អត់មែន។ឃើញថារយះពួកបងបានមានការបែកបាក់គ្នាជាច្រើន។
កៈ ចាស។
ខៈ គឺត្រូវតែមានការផ្សំផ្គុំដោយចាស់ទុំវិញ។
កៈ ចាស។

ខ៖ ដូចការផ្សះផ្សាដោយបងប្រុសប្រធានស្តេកហ្នឹង។
ក៖
អញ្ចឹងនៅក្នុងជំនាន់បងរៀបអាពាហ៍ពិពាហ៍ហ្នឹងតើមានដូចជាគេហៅថាថ្លៃបណ្ណាការការរីក៍ថ្លៃទឹកដោះអីគេដែរ?
ខ៖
អឺ!ពេលហ្នឹងថ្លៃបណ្ណាការការហ្នឹង!បងដូជាមិនទាន់ជាមានបរាក់ខែអីខ្លួនឯងដូចបងបានប្រាប់អញ្ចឹង!ការជំនះហាស!ហើយខាងឪពុកកមេកបងក៏គាត់មិនសូវជាយកថ្លៃដោយសារតែស្រលាញ់រាប់អានគ្នាអញ្ចឹងទៅហើយគាត់ក៏ចង់បានដូចគ្នាដែរព្រោះពេលហ្នឹងបងជាមនុស្សគ្រាន់ដែរហើយអញ្ចឹងទៅក៏បានការដល់ពេលក្រោយមកបងមិននឹកស្មានថាខ្លួនឯងគ្មានការគ្រប់គ្រងអារម្មណ៍ដូចរាល់ថ្ងៃបាន។
ក៖ ចាំស។
ខ៖ ព្រោះធ្វើអោយគាត់ពិបាកចិត្តច្រើន។
ក៖
ចាំស!ហើយតើបងរៀបរាប់បានទេពីពេលដំបូងដែលបងចាប់ផ្តើមជួបជាមួយនឹងភរិយារបស់បងហាស?
ខ៖
ពីដំបូងដូចជានេះទេ...បងផ្ទេរមករៀនហ្នឹងដូចបងបានប្រាប់អញ្ចឹង!បងបានផ្ទរមកៗរៀននៅអនុវិទ្យាល័យសេរីភាពហ្នឹងសាលាលិចទឹកគេហ្នឹង!បងរៀននៅថ្នាក់ទី៧ដំបូងបងព្រមផ្លោសតាមការ...ដំបូងបងរៀននៅបឋមបងរៀនពូកែ
ធ្លាក់ត្រឹមលេងបីហ្នឹងហើយដ៍អញ្ចឹងទៅការសៀវភៅតាមដានសៀវភៅអីគេហ្នឹងបានបងផ្ទេរមកយកមកដល់ទីរួមខេត្តហ្នឹងគេ!ក៏បានសួរថាចង់ផ្លោសអត់?ពីទី៧ផ្លោសទៅទី៩គិតទៅពីទី៦មកទី៩ផ្លោស៣ថ្នាក់។
ក៖ ចាំស។
ខ៖ អឹម!គាត់ចង់អោយផ្លោសអញ្ចឹងក៏ថា "ចាំមើលខ្ញុំសួរលោកតាហើយចាំសួរបងខ្ញុំសិនហើយបងគាត់បានអោយរៀនតាមលំដាប់ចូលរៀនទី៧វិញទៅ។
ក៖ ចុះបងរើនចប់ត្រឹមថ្នាក់ទីប៉ុន្មាន?
ខ៖ បានត្រឹមថ្នាក់ទី១២។
ក៖ ចាំស។
ខ៖ បងក្នុងពេលរៀនហ្នឹងក៏វារញ៉េរញ៉ៃទៀត។អឺ!គាត់សុំធីបអាការរៀនហ្នឹងចោល។
ក៖ ហើយបងរៀនសាលាជាមួយហ្នឹងភរិយារបស់បងដែរហ៎ស?
ខ៖ អត់ទេតែនៅរៀនសាលាជាមួយគ្នាក៏ប៉ុន្តែគាត់រៀនទី៨អញ្ចឹងទៅ។
ក៖ ចាំស។
ខ៖
ពេលហ្នឹង!ហើយគាត់ចប់ថ្នាក់ទី៨ហើយបងរៀនចប់នៅថ្នាក់បាក់ឌុបហ្នឹងមក។បងប្រលង

ហើយបងបានការជាមួយនឹងគាត់ពេលបងនៅរៀនហ្នឹងបងបានភ្ជាប់រយៈពេល៧ខែដែរពេលប្រលងហើយ....។
កៈ
អញ្ចឹងបានន័យថាអារបៀបដែរបងជួបបងស្រីហ្នឹងគឺនៅពេលដែលបងចាប់ផ្ដើមរៀនសាលាជាមួយនឹងគ្នាណ៎?
ខៈ អ៎!ពេលហ្នឹងបងជាមនុស្សខូចមួយបងបានតាមញ៉ែមិត្តភក្ដិគេក៏ប៉ុន្ដែការញ៉ែហ្នឹងមិនមែណជាលក្ខណៈថាមិនបានមានលក្ខណៈថាញ៉ែជា...ចង់បានជាគូរគាប់អីទេណា៎។
កៈ ចា៎ស។
ខៈ
ជារបៀបមនុស្សខូចមនុស្សប្រុសខូចហើយក្រោយមកក៏ពួកបងក៏មានការបែកគ្នា។ហើយអត់ដឹងថាខាងគ្រួសារបងហ្នឹងគេគេទៅរៀនថ្នាក់វ៉ាំងកងហ៎ស!ស្មានតែគេទៅណាបាត់!គេទៅនៅជាមួយបងប្រុសគេនៅស្ដីគេទេ...ហួសព្រែកហូយើងនៀក!ផ្ទះបងថ្លៃហ្នឹង!ទៅនៅជាមួយដល់ពេលចូលកងវិញគេមកវិញ "ចុមហើយទៅណាណី?" ដល់ពេលហើយ!ហើយពេលហ្នឹងក៏បានចូលរៀនទៅ
ហើយពេលហ្នឹងពេលទឹកលិចក៏មានអនិស្សាវរីយ៍ខ្លះដែរហើយក្រោយមកគេទៅចូលធ្វើការធ្វើអីហើយវ័យគេ២០ឆ្នាំស្ទើងហ្នឹងគេស្អាត់ដែរពេលហ្នឹង!ប្រពន្ធបងស្អាត។
មុខគាត់មានរោមមានអីអញ្ចឹងហើយដូចថាជាមនុស្សដែរស្រលាញ់ខ្លួនហើយអត់មានការផ្ដេសផ្ដាសជាមួយប្រុសរញ៉ែរញ៉ៃអីអញ្ចឹងទេ។ពេលទៅធ្វើការជិះរម៉កពីផ្ទះទៅ!ពីរោងចក្រ
ហើយពីរោងចក្រមកដល់ផ្ទះអីអញ្ចឹងទៅហើយបងឃើញថាចរិកមាយាទល្អអញ្ចឹងបងមានការស្ដាយអញ្ចឹងបានបង្ខំអោយបងប្រុសចូលស្ដីទៅក៏ពួកគាត់ចូលស្ដីអោយ។
កៈ ចូលស្ដីដណ្ដឹង?
ខៈ
ហ្នឹងហើយមុនដំបូងអត់ចង់ទេដល់ហើយទៅបានក្រោយមកគាត់មើលទៅខ្លាចបងធ្វើរញ៉ែរញ៉ៃបងធ្វើដូចជាចង់គំរាមគាត់អ្វីមួយគាត់ក៏ស្ដីអោយក៏ចូលស្ដីអញ្ចឹងទៅណា៎ស!ហ្នឹងហើយ!
ហើយបានឃើញថាគាត់បានយល់ពីចិត្តបងម៉េចៗទៅណាស់!បងគិតថាចង់បានប្រពន្ធនៅជិតស្និតជាមួយបងអញ្ចឹងទៅមើលខុសត្រូវគ្នាអញ្ចឹតទៅណា៎ស។
កៈ ចា៎ស។
ខៈ
ហើយគាត់គិតដល់ចិត្តបងចិត្តអញ្ចឹងហ៎ស!គាត់ថាយើងនៅក្មេង។និយាយរួមគឺដូចបងឃាត់ប្អូនប្រុសបងអញ្ចឹងពេលហ្នឹងហ៎ស!តែអត់ស្ដាប់ទេ!ការហើយវាមិនសមដូចការគិតក្នុងគំនិតយើងគិតដែរ។ប្រវិត្តជូរចត់ការក្រោយការហើយ។
កៈ ចា៎ស!។
ខៈ
មានការល្បួងជាច្រើនខាងច្បាប់ព្រហ្មចារីយភាពពីមួយទៅមួយអញ្ចឹងញ៉ែលិចញ៉ែកើតអញ្ចឹ

ងទៅមានការល្បួងពី(...អាកាលហ្នឹងរត់ម៉ូតូ)មានការល្បួងពីកូនដុកទ័រហើយនឹងម្ដាយគេ(គាត់ហ្នឹងជាដុកទ័រធ្មបមួយនៅចាក់អង្រែយើងហ្នឹង!ប៉ុន្តែពេលហ្នឹងបងថាបងបែកគ្នាជាមួយគ្រួសារហ្នឹង។
កៈ ចា៎ស។
ខៈ
អឺម!អញ្ចឹងគេមានការរៀបចំកូនគេហ្នឹងប្រុងធ្វើផ្ទះធ្វើអីអោយនៅទៀតហា៎ស!ហើយករហ្នឹងមិនបាច់ខាងបងទៅក៏បានដែរអោយតែព្រមការទៅ។តែពេលហ្នឹងធ្វើយ៉ាងម៉េចទៅមាននាក់បងប្អូនគេហ្នឹងគេមកការបងហ៎ស!ហើយគេសួរនាំបងថាយ៉ាងម៉េចហើយប្រពន្ធកូន?អញ្ចឹងទៅក៏ពួកគាត់បានដឹង
ពួកគាត់បានដឹងទៅហើយក៏សួរនាំទៅថាបើមានបញ្ហាអីទៅនិយាយសំរួលជាមួយប្រពន្ធកូនវិញទៅកុំ...គាត់ហ្នឹងគាត់ស្លូតដែរគាត់បានអត់មានបញ្ហាអីអញ្ចឹងហ៎ាស!។
កៈ ចា៎ស។
ខៈ
ហើយគាត់ក៏លេងម៉ាត់អីដល់រាល់ថ្ងៃហ្នឹងទៅ។ហើយបងគិតថាបងមិនអាចទៅណារួចពីកូនទាំងពីរហ្នឹងដែរ។
កៈ ហ្នឹង។
ខៈ
ទៅដល់ណាក៏នឹកឃើញវា(មានពីណាមើលវាស្រីផងអីផង)នឹកឃើញតែប៉ុន្នឹងបានម្ដងពេលៗទៅឆ្ងាយបាននឹកឃើញដល់ពេលមកកអីអញ្ចឹងទៅក៏មានការល្បួងផឹកអី..ក៏ទៅផឹកបាត់អញ្ចឹងទៅអូយ!វេទនាណាស់។
កៈ តែមនោសញ្ចេតនាក៏មិនអាច់កាត់ផ្ដាច់បានដែរ។
ខៈ
អត់កាត់ដូចកាត់មិនដាច់ទោះបីជាអ្នកហ្នឹងស្អាតយ៉ាងម៉េចក៏ដោយហើយល្បួងទ្រព្យសម្បត្តិយ៉ាងម៉េចក៏ដោយក៏ចេញពីជីវិតពីកូនទាំងពីរនឹងប្រពន្ធអត់បានដូចគ្រូហោរាដែលបានទាយទុកនោះអត់ខុសមែន។
កៈ ចា៎ស។
ខៈ បើតាមបងសង្កេតមើល។
កៈ
ចា៎ស!អញ្ចឹងបងបើសិនជាបងក្រឡេកមកមើលពីជីវិតរបសបងតាំងពីតូចរហូតមកដល់ឥលូវតើបងឃើញថាជីវិតរបស់បងមានការផ្លាស់ប្ដូរបែបណាដែរ?
ខៈ
បើតាំងពីតូចមក!បើពីតូចមកគឺបងចង់ត្រលប់ទៅពីតូចវិញ។ហើយអោយវាសារមកពីតូចរហូតមកដល់ធំវិញហើយបងចង់អោយបងមានគំនិតពីតូចហ្នឹងមកល្អ។បងចង់ធ្វើជាដុកទ័រអីណាណ៎!ប៉ុន្តែដោយគ្មានការឧបបមជាច្រើន។
កៈ ចា៎ស។

ខ៖
ហើយការរៀនហ្នឹងវា...អាហ្នឹងសំរាប់បើអ្នកគេមានការតស៊ូហ្នឹង!គេនឹងថាបងជាមនុស្សអត់តស៊ូទេ
ហើយប្រវិត្តបងប្រាប់ប្អូនហ្នឹងអត់តស៊ូទៀតអត់ដឹងប្រាប់ថាយ៉ាងម៉េចក្នុងការបន្តរការរៀននៅអនុវិទ្យាល័យរហូតដល់វិទ្យាល័យហ្នឹង។
ក៖ ចាំស!អញ្ចឹង...។
ខ៖
ពេលរៀន..ចេញពីរៀនទៅណាដឹងហើយ!គឺទៅយកបាយជ្រូកចិញ្ចឹមជ្រូក។ប្រវិត្តកាលពីនៅរៀនគឺអត់មានពេលសំរាកញែកពេលរៀនបានស្រួលទេ
មកពីរៀនមកគឺដល់ម៉ោងធ្វើការ ចិញ្ចឹមជ្រូកអីអញ្ចឹងទៅធ្វើម្ហូបយកទៅគេនៅផ្សារហើយអញ្ចឹងទៅចំថ្ងៃដែលយើងត្រូវរៀនហ្នឹងនៅជួយលក់គេរហូតដល់ចង់ផុតម៉ោងហួសរៀនអង់គ្លេសនៅសេះសរយើងហ្នឹង។
ក៖ ចាំស។
ខ៖ នៅ យ៉ូ អេស ស្អេ យើងហ្នឹង!ហើយជួលកាលរៀនហួសថ្ងៃគេចូលជិតមួយអាទិត្យអីអញ្ចឹងទៅ។ក៏អោយសូមគេច្បាប់អ៎!ក៏សូមអោយគេបន្ថយថ្លៃតិចទៅ(តែបន្ថយថ្លៃយ៉ាំងម៉េចទៅគិតទៅទាំងយើងទាំងគេ)រយះពេលចង់មួយអាទិត្យទៅហើយ។
ក៖
និយាយទៅបងគឺតាំងពីតូចរហូតមកដល់ឥលូវគឺជីវិតគឺជីវិតរបស់បងម្យ៉ាងម្នាក់មានជីវិតបែបជូរច៉ត់ហើយហ្នឹងបញ្ហាផ្សេងៗនៅក្នុងជីវិតរបស់បងកាលពីក្មេងរហូតមកដល់ធំណេះ!អញ្ចឹងក៏ឆ្ងល់ដែរថាតើបងអាចឆ្លងកាត់នៅឧបស្គគដែលលំបាកៗហ្នឹងដោយរបៀបណាដែរបង?
តើមានអ្វីដូចថាជាជំរុញទឹកចិត្តបង?តើអ្វីដែលជាក្តីសង្ឃឹមរបស់បងដែរបងអាចឆ្លងកាត់ឧបស្គគទាំងអស់ហ្នឹងរហូតមកដល់ឥលូវហាស!។
ខ៖
អ៎!ពីមុនមកដូចបងបានប្រាប់អញ្ចឹងមានតែកែវភ្នែកដ៏ខ្មៅទាំងពីរហ្នឹងទាំងបួនហ្នឹងដែរបងមានការតស៊ូហើយនឹងមើលឃើញនៅចិត្តដ៏ល្អរបស់ភរិយាបងហ្នឹង។
ក៖ ចាំស។
ខ៖
ហើយនឹងការតាំងចិត្តការថែខ្លួនរបស់គេគឺអត់មានការភ្លើតភ្លឺនអីជាច្រើនតាំងពីបងស្គាល់គេពីក្មេងរហូតដល់គាត់មានកូនដល់ទៅពីរហ្នឹងជាមួយនឹងបង។អញ្ចឹងទៅគឺជាគ្រឹះដ៏មាំសំរាប់បងក្នុងការស្រលាញ់ដល់គ្រួសារហ្នឹងហើយបន្ថែមហ្នឹងគឺបងបានស្គាល់នៅព្រះដ៏ពិតហើយហ្នឹងដំណឹងល្អរបស់ទ្រង់ធ្វើអោយពួកបងទាំងគ្រួសារមានការប្រែចិត្តហើយនឹងមានការបំផុសគំនិតជាច្រើនអោយមានការយល់ដឹងពីគ្រួសារដ៏ល្អមានការសុខសប្បាយជាច្រើនសំរាប់ទ្រង់ផ្តល់អោយពួកយើង។

កៈ ចាំស!អញ្ចឹងហ្នឹងគឺជាបញ្ហាទាំងឡាយដូចថា...ដែរបងបានរៀបរាប់មក។
ខៈ បាទ។
កៈ
ចុះបើគិតពីបទពិសោធ៍ដែរល្អៗវិញតើបងចាំពីបទពិសោធអីខ្លះពីជវិតរបស់បងដែរគិតថាវាជាអី!...ចង់និយាយថាយើងធ្លាប់ឆ្លងកាត់នៅបទពិសោធ៍ដែរល្អៗហ៎ាស!?
ខៈ
បទពិសោធ៍ល្អរបស់បងគ្មានអីក្រៅតែពីការលក់ដូរហ្នឹងទេ!ការលក់ដូររបស់បងដូចជាគេហៅថាអញូនកជំនាញមួយក្នុងការលក់ហ៎ាស!។
កៈ ពូកែលក់ហ៎ាស?
ខៈ
ហ្នឹងហើយ!គឺពូកែប្រសព្វធ្វើឆ្លូត!និយាយទៅជាជីវិតបាតផ្សារមួយមិនមែលណាថាបាតផ្សារហ្នឹងជាមនុស្សក្មេងរញ៉េរញ៉ៃអីទេគ្រាន់តែថាជីវិតបាតផ្សារយងគឺជាអ្នកលក់មួយដែរមិនចេះខ្មាស់អៀនជាមនុស្សប្រុសមួយដែរមិនចេះខ្មាស់អៀនក្នុងការលក់ហ៎ាស!ព្រោះអីក្នុងការលក់ហ្នឹងដែរ
រាល់ការអឺ!អ៊ុំរបស់បងហើយនឹងបងប្រុសរបស់បងដែរបានផ្ដល់អោយបងនៅការអោយបង្ហាល់នៅការលក់ដូរ
ទោះបីបងមិនបានបន្តរនៅការសិក្សានៅមហាវិទ្យាល័យសាកលវិទ្យាល័យអីក៏ដោយក៏បងបានស្គាល់នៅការចេះលក់ដូរមួយពីពួកគាត់ជាជំនាញមួយពីពួកកាត់ក្នុងការលក់ដូរ។
កៈ និយាយទៅគឺបងពូកែទ្រីស្ដីសំដីបាន។
ខៈ
អឺ!ដូចគេថាដែរក៏គ្រាន់តែថាប៉ុន្តែបើការលក់ហ្នឹងយើងចេះនិយាយអីអញ្ចឹងហ្នឹងហ៎ាស!បានហើយក៏ប៉ុន្តែថាអោយទៅរកស៊ីជាអ្នកធ្វើការមុនរបរជាជំនួយធំដុំអីគឺបងអត់ទាន់មានអាការរើនហ្នឹងច្រើនដូចគេទេបើថាគ្រាន់តែលក់នៅទីផ្សារអីបងអាចលក់បាន។
កៈ ចាំស។
ខៈ ហើយជាជំនាញមយយបន្តរពីពួកគាត់មក។
កៈ ជាទេព្យកោរសល្លមួយហ៎ស?
ខៈ បាទជាទេព្យកោរសល្យមួយសំរាប់ការចិញ្ចឹមជីវិតបន្តរពីមុនមក។
កៈ
ចាំស!អញ្ចឹងទាក់ទងជាមួយហ្នឹងចំណង់ចំនូលចិត្តរបស់បងវិញហ៎ាស!តើបងមានចំណង់ក្នុងការធ្វើអីដែរ?ឧទារហណ៍ជាម្ហូមវែក៏ជាកីឡាណាមួយរឺល្បែងណាផ្សេងៗដែរបងចូលចិត្តតាំពីនៅតូចមកអញ្ចឹងហ៎ាស?
ខៈ
អឺ!បើជារបរនិយាយអោយអស់ពីកាលចង់រកស៊ីរាល់ថ្ងៃបើ..មានគឺចង់បានតែជំនាញចុងភៅមួយទេហើយជាចំណង់តាំងពីបងគិតថាចង់ធ្វើរបរហ្នឹងមកគិតថាបងចង់ធ្វើមែនទែនគឺជំនា

ញចុងភៅហ្នឹង។ហើយបងវាអត់មានលទ្ធភាពក្នុងការទៅរៀនជាមួយគ្រូដ៏ល្អៗដូចជាគ្រូបរទេសអីអញ្ចឹងទៅណាស។
ក៖ ចាស។
ខ៖
បើបងមានធនធានដូចកូនអ្នកដទៃដែរគេមានបានអាហ្នឹងបងចង់សូមម៉ែឪហ្នឹងទៅរៀននៅអាជំនាញម្ហូបមួយ។
ក៖ ចាស។
ខ៖
ហើយបងចង់បង្កើតម្ហូបមួយសំរាប់ជនជាតិនឹងសំរាប់អាហារអ្នកស្រុក។អូ!អាហ្នឹងមិនធម្មតាទេ។
ក៖
ចាស!អញ្ចឹងអាហ្នឹងក៏ជាក្ដីស្រម៉ៃនឹងជាក្ដីសង្ឃឹមមួយដែរបងចង់ធ្វើនៅពេលអនាគតដែរមែនទេ?
ខ៖ បាទ។
ក៖ ចុះតាំងពីតូចមកដល់ធំតើបងដែលមានក្ដីស្រម៉ៃចង់ធ្វើអីផ្សេងទៀតទេ?
ខ៖
បងអត់មានអីក្រៅពីហ្នឹងទេហើយបើមានការបន្ទាប់បន្សំមួយគឺការចិញ្ចឹមសត្វអីអញ្ចឹងទៅណាស។
ក៖ ចាស។
ខ៖
ហ្នឹងហើយជាការបន្ទាប់បន្សំរបស់បង។ហើយការចំណង់នោះគឺចង់ធ្វើជាចុងភៅមួយដ៏ចំណានសំរាប់គ្រួសារហើយនឹងអាជិវកម្មបងទៅមុខទៀត។
ក៖
និយាយទៅអាហ្នឹងវាទាក់ទងជាមួយហ្នឹងការខំប្រឹងប្រែងតស៊ូដើម្បីអឺ!ដើម្បីអនាគតហើយនឹងក្ដីស្រម៉ៃទៅមុខទៀតអោយកើតឡើងណេះ?ដោយមិនមែនគ្រាន់តែជាការគិតតែវាធ្វើអោយយើងមាននៅទង្វើដែលធ្វើអោយកើតឡើង។អញ្ចឹងប្រសិនជាបងមានពាក្យអ្វីដែរផ្ដាំផ្ញើរទៅដល់កូនៗរបស់បងកូនស្រីរបស់បងរឺក៏ចៅរបស់បងនៅពេលខាងមុខរឺក៏អនាគតអីអញ្ចឹងតើបងមានពាក្យអ្វីខ្លះចង់ទូន្មានដល់គាត់រឺចង់ផ្ដាំផ្ញើរអោយពួកគាត់ហាស!អោយបានដឹង?
ខ៖
បងមានពាក្យខ្លអសំរាប់កូនស្រីទាំងពីរបងបានផ្ដល់នៅការទូន្មានជាច្រើនសមរាប់កូនស្រីបងដោយការ!ការងារផ្ទះនឹងទូនាទីខ្លួនជាស្រីដើម្បីអោយពួកគាត់បានដឹងថាតួនាទីខ្លួនជាស្រីថាមានតួនាទីអីខ្លះអញ្ចឹងទៅហើយខ្ញុំចង់អោយគាត់យល់ពីការងារហ្នឹងជាច្រើនអោយពួកគាត់យល់ដល់ពេលគាត់មានគ្រួសារគាត់អត់មានការខ្វះខាត់នៅការទាំងហ្នឹងក្នុងការពេញចិត្តដូចការដែរបងពេញចិត្តគ្រួសារអូនអែងដែរហើយអោយគាត់យ៉ាងហោចណាស់អោយ

គាត់ចេះធ្វើម្ហូបខ្លះៗសំរាប់គ្រួសារពេលដែលគាត់មានគ្រួសារទៅដើម្បីកុំអោយគេថាមនុស្ស ស្រីបង្វាល់ចង្កានមិនជុំ។

កៈ ចាំស!អញ្ជឹងអរគុណបង នីន ខ្លាំងបំផុតជាពិសេសសំរាប់ពេលវេលានឹងឪកាសដែរបងបានចែកចាយរៀបរាប់ពីជីវិតជូរចត់ហើយហ្នឹងបទពិសោធ៍ផ្សេងទាំងល្អនឹងទាំងអាក្រក់លំបាកទៅដល់យើងទាំងអស់គ្នាផង ដែរអញ្ជឹងអរគុណបងមែនទែន។